01330276

**Declassified to Public**
**12 June 2020**

លេខ / N°: D301/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 27-Sep-2016, 09:21
CMS/CFO: Ly Bunloung

សំណុំរឿងលេខៈ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦

ភាសា ៖ អង់គ្លេស [ភាសាដើម]

ចំណាត់ថ្នាក់ឯកសារ ៖ សម្ងាត់

---

# ដីកាសម្រេចរួមលើសំណើសុំកិច្ចស៊ើបសួរពាក់ព័ន្ធនឹង ឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ និង បង្កឲ្យមានផ្ទៃពោះដោយបង្ខំ

---

ផ្ញើជូន៖

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**
មុំ លុច
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម ទិត្យ**
SO Mosseney

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**
ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវន
ទី ស្រីនណា
វ៉ែន ពៅ

Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

Suzana TOMANOVIĆ

Linda BEHNKE
Laure DESFORGES
Herve DIAKIESE

# I. ប្រវត្តិនីតិវិធី

1. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣, ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ និង ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥។

2. នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ដោយស្នើឲ្យ ស.ច.ស បើកកិច្ចស៊ើបសួរតាមផ្លូវតុលាការក្នុងអង្គហេតុ ដែលបានចោទប្រកាន់ក្នុងដីកានោះ (“ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី”)[1]។

3. នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនៅតំបន់ ១ និង ការធ្វើទុក្ខបុកម្នេញខ្មែរក្រោម[2]។

4. នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង អំពើហិង្សាផ្លូវភេទ ឬ យេនឌ័រ ក្នុងសំណុំរឿង ០០៤ (“ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម”)[3]។

5. នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតមុន បានចោទប្រកាន់ អោ អាន ពីបទរំលោភបំពានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពាក់ព័ន្ធនឹងការធ្វើមនុស្សឃាត, ការសម្លាប់រង្គាល, ការធ្វើទុក្ខបុកម្នេញ និង ការដាក់ក្នុងមន្ទីរឃុំឃាំង និង អំពើអមនុស្សធម៌ផ្សេងៗទៀត[4]។

6. នៅថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តនៅវត្តតាមាឃ[5]។

7. នៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥ យើងបានចោទប្រកាន់ យឹម ទិត្យ ពីបទអំពើប្រល័យពូជសាសន៍, អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩, ការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ

---

[1] សំណុំរឿងលេខ 004-D1, *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញា*, ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨។

[2] សំណុំរឿងលេខ 004-D65, *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនៃតំបន់ ១ និង ការធ្វើទុកបុកម្នេញខ្មែរក្រោម*, ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១។

[3] សំណុំរឿងលេខ 004-D191, *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង អំពើហិង្សាផ្លូវភេទ ឬ យេនឌ័រ*, ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤។

[4] សំណុំរឿងលេខ 004-D242, *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង*, ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥។

[5] សំណុំរឿងលេខ 004-D254/1, *ចម្លើយតបទៅដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវត្តអង្គតាមាក់*, ចុះថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០១៥។

១៩៥៦, និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពាក់ព័ន្ធនឹងការធ្វើមនុស្សឃាត, ការសម្លាប់រង្គាល, ការធ្វើឲ្យទៅជាទេសករ, ការដាក់ក្នុងមន្ទីរឃុំឃាំង, ការធ្វើទារុណកម្ម, ការធ្វើទុក្ខបុកម្នេញ និង អំពើអមនុស្សធម៌ផ្សេងៗទៀត[6]។

8. នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៦ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានដាក់សំណើសុំកិច្ចស៊ើបសួរប្រឆាំងនឹងសំណើរបស់ អោ អាន និង យឹម ទិត្យ ដែលស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតចាត់កិច្ចស៊ើបសួរលើការមានផ្ទៃពោះដោយបង្ខំ ជាបទឧក្រិដ្ឋមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពាក់ព័ន្ធនឹង"អំពើអមនុស្សធម៌ផ្សេងៗទៀត" ("សំណើមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី")[7]។

9. នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ យើងបានចោទប្រកាន់ អោ អាន បន្ថែមលើបទចោទនៃអំពើប្រល័យពូជសាសន៍ និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ ដែលត្រូវបានប្រព្រឹត្តនៅទីតាំងឧក្រិដ្ឋកម្មបន្ថែមទៀត[8]។

10. នៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ មេធាវីការពារក្ដី យឹម ទិត្យ ដាក់សារណាតបដោយជំទាស់ទៅនឹងសំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ("សំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី")[9]។

11. នៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ចម្លើយតបគាំទ្រសំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និង បានលើកឡើងថា ជំនួសឲ្យការមានផ្ទៃពោះដោយបង្ខំ, សហចៅក្រមស៊ើបអង្កេតគប្បីចាត់កិច្ចស៊ើបសួរលើការមានគភ៌ដោយបង្ខំ ក្រោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពាក់ព័ន្ធនឹង"អំពើអមនុស្សធម៌ផ្សេងៗទៀត" ("សំណើសហព្រះរាជអាជ្ញាអន្តរជាតិ")[10]។

12. នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៦ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានដាក់ការឆ្លើយតបទៅនឹងចម្លើយតបរបស់មេធាវី យឹម ទិត្យ ("ការឆ្លើយតបរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី")[11]។

---

[6] សំណុំរឿងលេខ 004-D281, *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង*, ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥។

[7] សំណុំរឿងលេខ 004-D301, *សំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំបំពេញកិច្ចស៊ើបសួរប្រឆាំង អោ អាន និង យឹម ទិត្យ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មស្តីពីការមានផ្ទៃពោះដោយបង្ខំ*, ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៦។

[8] សំណុំរឿងលេខ 004-D303, *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ អោ អាន*, ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦។

[9] សំណុំរឿងលេខ 004-D301/1, *ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងសំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំបំពេញកិច្ចស៊ើបសួរប្រឆាំង អោ អាន និង យឹម ទិត្យ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មស្តីពីការមានផ្ទៃពោះដោយបង្ខំ*, ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦។

[10] សំណុំរឿងលេខ 004-D301/2, *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងបទឧក្រិដ្ឋស្តីពីការមានផ្ទៃពោះដោយបង្ខំ*, ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦។

[11] សំណុំរឿងលេខ 004-D301/1/1, *សារណាតបរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ទៅនឹងចម្លើយតបរបស់មេធាវីការពារក្ដី យឹម ទិត្យ ទៅលើសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងឧក្រិដ្ឋកម្មស្តីពីការមានផ្ទៃពោះដោយបង្ខំ*, ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៦។

## II. សារណា

### ក) សំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

13. មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ស្នើឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស.") បំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងចេតនារបស់ អោ អាន និង យឹម ទិត្យ ក្នុងការអនុវត្តរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់អន្តរជាតិ តាមរយៈការចាប់ស្ត្រីដាក់មន្ទីរឃុំឃាំង និង បង្ខំឲ្យមានផ្ទៃពោះ[12]។ ប្រសិនបើរកឃើញចេតនានេះ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំឲ្យចោទប្រកាន់ យឹម ទិត្យ និង អោ អាន ពីបទមានផ្ទៃពោះដោយបង្ខំ ជាបទឧក្រិដ្ឋមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពាក់ព័ន្ធនឹង"អំពើអមនុស្សធម៌ផ្សេងៗទៀត" អនុលោមតាមមាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ("ច្បាប់ អ.វ.ត.ក")[13]។

i. <u>នីត្យានុកូលភាព</u>

14. មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី លើកឡើងថា ការស៊ើបអង្កេត និង ចោទប្រកាន់ពីបទមានផ្ទៃពោះដោយបង្ខំ ជាបទឧក្រិដ្ឋមួយក្នុងអំពើអមនុស្សធម៌ផ្សេងៗទៀតនៅ អ.វ.ត.ក មិនរំលោភលើគោលការណ៍នីត្យានុកូលភាពនោះទេ ដោយសារការប្រកាសស៊ីសង្វាក់គ្នារបស់អង្គបុរេជំនុំជម្រះ និង អង្គជំនុំជម្រះសាលាដំបូងថា"អំពើអមនុស្សធម៌ផ្សេងៗទៀត" គឺជាប្រភេទបទឧក្រិដ្ឋគ្រប់គ្រាន់ដោយខ្លួនឯង និង បង្កើតបានជាផ្នែកមួយនសច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅមុនឆ្នាំ ១៩៧៥[14]។

ii. <u>ធាតុផ្សំនៃ"អំពើអមនុស្សធម៌ផ្សេងៗទៀត" ដូចកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង</u>

15. មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី លើកឡើងថាការប្រព្រឹត្តិដែលបង្កើតបានជាការមានផ្ទៃពោះដោយបង្ខំ បំពេញធាតុផ្សំនៃ"អំពើអមនុស្សធម៌ផ្សេងៗទៀត" ដូចដែលមានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង ជាអាទិ៍៖ (i) អំពើសកម្ម ឬ អកម្មដែលបណ្ដាលឲ្យមានព្យសនកម្មធ្ងន់ធ្ងរមកលើរាងកាយ ឬ ផ្លូវចិត្ត ឬ បង្កឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ (ii) អំពើសកម្ម ឬ អកម្មដែលបានប្រព្រឹត្តឡើងដោយមានចេតនាបង្កការឈឺចាប់យ៉ាងធ្ងន់ធ្ងរ មកលើរូបរាងកាយ ឬ ផ្លូវ

---

[12] សំណើមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី កាថាខណ្ឌ ១, ៣, ៦៤, ៦៥។

[13] សំណើមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី កាថាខណ្ឌ ៦៥។

[14] សំណើមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី កាថាខណ្ឌ ១៩-២២។

ចិត្ត ឬ ប្រព្រឹត្តអំពើហិង្សាយ៉ាងធ្ងន់ធ្ងរ មកលើជនរងគ្រោះ ដែលធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្សជាតិ នៅពេលដែលបានប្រព្រឹត្តអំពើសកម្ម ឬ អកម្មនោះ និង (iii) អំពើសកម្ម ឬ អកម្មមានលក្ខណៈ និង ស្ថានទម្ងន់ស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាក់លាក់ផ្សេងទៀត ដែលភាពធ្ងន់ធ្ងរនៃអំពើនេះ គឺត្រូវបានវាយតម្លៃដោយផ្អែកតាមករណីនីមួយៗ ដោយពិចារណាលើកាលៈទេសៈរបស់បុគ្គលនីមួយៗនៅក្នុងរឿងក្តីនោះ[15]។

16. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញសម្អាងដោយដកស្រង់ភ័ស្តុតាងនៃការឈឺចាប់ពាក់ព័ន្ធនឹងការមានផ្ទៃពោះ និង ការរងទុក្ខដែលហួសពីព្យសនកម្មនៃការមានផ្ទៃពោះធម្មតា និង ដែលបណ្តាលមកពីកាលៈទេសៈជាក់លាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ("របបកម្ពុជាប្រជាធិបតេយ្យ")[16]។

17. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញធាតុផ្សំទីពីរ ដោយយោង និង ពឹងផ្អែកលើការចោទប្រកាន់របស់សហព្រះរាជអាជ្ញានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ពាក់ព័ន្ធនឹងតួនាទីរបស់ យឹម ទិត្យ និង អោ អាន ក្នុងការប្រព្រឹត្តិ រៀបចំផែនការ ញុះញង់ បញ្ជា ឬ ជួយក្នុងការអនុវត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[17]។

18. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អះអាងថាការប្រព្រឹត្តិនោះ មានលក្ខណៈ និង ស្ថានទម្ងន់ស្រដៀងគ្នាបទឧក្រិដ្ឋជាក់លាក់ឯទៀត ដោយបានសម្អាងលើអំណាងអំណាងរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក្នុងសំណុំរឿង *Kupreškić* ស្តីពីបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ សម្រាប់កំណត់អំពើអមនុស្សធម៌ដែលត្រូវហាមឃាត់[18]។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុវត្តតាមវិធីសាស្ត្រនោះ ដោយកំណត់បទដ្ឋានខាងក្រោមនេះ ដែលពួកគាត់លើកឡើងថា បង្ហាញថាការមានផ្ទៃពោះដោយបង្ខំ ជាអំពើដែលមានស្ថានទម្ងន់ប្រហាក់ប្រហែលគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដទៃទៀត ដែលមានកំណត់ជាក់លាក់នៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក៖

---

[15] សំណើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២៥, ដកស្រង់សំណុំរឿងលេខ 002-E313, សាលក្រម, សំណើចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៣៧-៤៣៨។

[16] សំណើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២៩-៤១។

[17] សំណើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៤២។

[18] សំណើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៤៧, ដកស្រង់ករណី *ព្រះរាជអាជ្ញា ទល់នឹង Kupreškić, សាលក្រម*, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-16-T), ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០, កថាខណ្ឌ ៥៦៦។

ក) មាត្រា ១៧ នៃដំណោះស្រាយ XVII របស់សន្និសីទអន្តរជាតិនៃទីក្រុងតេហេរ៉ង់ ស្តីពីសិទ្ធិមនុស្ស ឆ្នាំ ១៩៦៨ ដែលចែងថា មាតាបិតាមានសិទ្ធិមនុស្សជាមូលដ្ឋាន ក្នុងការសម្រេចដោយសេរី និង ដោយមានការទទួលខុសត្រូវចំពោះភាពរង្វើលនៃការមានកូន។

ខ) មាត្រា ៧(១)(ឆ) និង (២)(ច) នៃលក្ខន្តិកៈក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិឆ្នាំ ១៩៩៨ (“លក្ខន្តិកៈក្រុងរ៉ូម”) ដែលកំណត់និយមន័យ និង ដាក់ឲ្យក្លាយជាបទឧក្រិដ្ឋចំពោះ ការមានផ្ទៃពោះដោយបង្ខំ និង

គ) លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន និង ក្រុមប្រឹក្សាពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅប្រទេសទីម័រខាងកើតឆ្នាំ ២០០០ ដែលបញ្ចូលបញ្ញត្តិដាក់ការមានផ្ទៃពោះដោយបង្ខំជាបទឧក្រិដ្ឋ[19]។

iii. <u>ធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ</u>

19. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដកស្រង់ការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យជំនុំជម្រះ ថាមានហេតុផលដែលជឿថាធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានបំពេញដោយការអនុវត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង អះអាងថា ការអនុវត្តការមានផ្ទៃពោះដោយបង្ខំ នឹងបំពេញធាតុផ្សំទាំងនោះដូចគ្នា[20]។

iv. <u>ការមានផ្ទៃពោះដោយបង្ខំមានលក្ខណៈខុសគ្នាពីបទឧក្រិដ្ឋជាក់លាក់ដទៃទៀត</u>

20. នៅទីបញ្ចប់ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ការមានផ្ទៃពោះដោយបង្ខំតម្រូវឲ្យមានការស៊ើបអង្កេត និង ការចោទប្រកាន់មួយដោយខ្លួន ដោយសារតែវាពាក់ព័ន្ធនឹងលក្ខណៈវិនិច្ឆ័យជាក់លាក់មួយ ដែលធ្វើឲ្យវាខុសគេពីអំពើជាក់លាក់ដទៃទៀត ដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក[21]។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពឹងផ្អែកលើនិយមន័យនៃការមានផ្ទៃពោះដោយបង្ខំក្នុងលក្ខន្តិកៈក្រុងរ៉ូម ដែលមានចែងដូចគ្នានៅក្នុងបញ្ញត្តិរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ដោយលើកឡើងថា “*ការតាក់តែងច្បាប់ព្រហ្មទណ្ឌស្តីពីការមានផ្ទៃពោះដោយបង្ខំរបស់តុលាការទាំងពីរនេះ បញ្ជាក់ពីការយល់ដឹងទូទៅអំពីនិយមន័យរបស់វាក្នុងច្បាប់អន្តរជាតិ។ ធាតុផ្សំជាក់លាក់នៃ*

[19] សំណើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៤៧។

[20] សំណើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៤៩។

[21] សំណើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៥០។

*ឧក្រិដ្ឋកម្មដែលមានចែងក្នុងច្បាប់ទាំងនេះ សុទ្ធតែអាចអនុវត្តបាននៅ អ.វ.ត.ក"*[22]។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី លើកឡើងថា ការប្រព្រឹត្តិនេះ ដែលបង្កើតបានជាការមានផ្ទៃពោះដោយបង្ខំ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនេះ បំពេញតាមលក្ខខណ្ឌនៃនិយមន័យក្នុងលក្ខន្តិកៈក្រុងរ៉ូម[23]។

v. <u>សហចៅក្រមស៊ើបអង្កេត ទទួលបានអង្គហេតុពាក់ព័ន្ធនឹងការមានផ្ទៃពោះដោយបង្ខំ</u>

21. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ជំទាស់ថា សំណើរបស់ពួកគាត់មិនពាក់ព័ន្ធនឹងការស៊ើបអង្កេតលើ"អង្គហេតុថ្មី"នោះទេ។ ប៉ុន្តែ វាស្ថិតក្នុងវិសាលភាពនៃការចោទប្រកាន់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[24]។

**ខ) ការឆ្លើយតបរបស់មេធាវីការពារក្តី**

22. មេធាវីការពារក្តី យឹម ទិត្យ ជំទាស់សំណើរបស់សហព្រះរាជអាជ្ញា ដោយសម្អាងលើ (i) ការសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដាក់យឺតពេល និង ថាការស៊ើបអង្កេតណាមួយដែលធ្វើឡើងទៅតាមសំណើនោះ នឹងប៉ះពាល់ដល់សិទ្ធិរបស់ យឹម ទិត្យ ក្នុងការទទួលបានការជំនុំជម្រះដោយមិនពន្យារពេលឥតចាំបាច់[25] (ii) សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីផុតពីដែនសមត្ថកិច្ច ដោយសារពួកគាត់ស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតទទួលការចោទប្រកាន់លើអង្គហេតុថ្មី ដែលហួសពីតួនាទីដើមបណ្តឹងរដ្ឋប្បវេណី ហេតុដូច្នេះសំណើនោះមិនអាចទទួលយកបាន[26] និង (iii) សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនបានបង្ហាញអំពីថាតើការស៊ើបអង្កេត នឹងផ្តល់ផលប្រយោជន៍ដល់ព័ត៌មានដោះបន្ទុកដោយរបៀបណា និង ខ្វះមូលហេតុបឋមពាក់ព័ន្ធនឹងថាតើហេតុអ្វីបានជាកិច្ចស៊ើបសួរ មានភាពពាក់ព័ន្ធនឹងការបង្ហាញការពិតអំពីអង្គហេតុ ដូចដែលបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០៤[27]។

23. មេធាវីការពារក្តី យឹម ទិត្យ លើកឡើងបន្ថែមថា សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំស៊ើបអង្កេតអង្គហេតុដែលស្ថិតក្រៅវង្វង់វិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើក

---

[22] សំណើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៥១-៥២។

[23] សំណើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៥៣-៥៦។

[24] សំណើមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៦០-៦៣។

[25] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ៦-៩។

[26] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ១០-១២។

[27] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ១៣-១៥។

ទីបី ដែលនៅក្នុងដីកានោះមិនបានចោទប្រកាន់ជាក់លាក់អំពីការមានផ្ទៃពោះដោយបង្ខំ ឬ អត្ថិភាពនៃគោលនោបាយជាតិក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំនេះនោះទេ[28]។ ដូច្នេះ មេធាវីការពារក្តីលើកឡើងថា ការស៊ើបអង្កេតណាមួយលើអង្គហេតុ ដូចដែលអះអាងក្នុងសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី នឹងប៉ះពាល់ដល់គោលការណ៍សច្ចភាពផ្លូវច្បាប់ ដោយសារវាពាក់ព័ន្ធនឹងការការពង្រីកបទឧក្រិដ្ឋ ដែលកំពុងត្រូវបានស៊ើបអង្កេតប្រឆាំងនឹង យឹម ទិត្យ[29]។

### គ) សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ

24. សហព្រះរាជអាជ្ញាអន្តរជាតិ គាំទ្រសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី[30] ប៉ុន្តែ លើកឡើងថា និយមន័យលក្ខន្តិកៈក្រុងរ៉ូមអំពីការមានផ្ទៃពោះដោយបង្ខំ មិនគប្បីផ្ទេរដោយស្វ័យប្រវត្តិមក អ.វ.ត.ក បាននោះទេ ដោយសារវាមិនឆ្លុះបញ្ចាំងនូវច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅអំឡុងឆ្នាំ ១៩៧៥-១៩៧៩[31]។ នេះគឺដោយសារតែការព្រៀងនិយមន័យនៃការមានផ្ទៃពោះដោយបង្ខំនៅក្នុងលក្ខន្តិកៈក្រុងរ៉ូមពាក់ព័ន្ធនឹងការស្រុះស្រួលគ្នារវាង់រដ្ឋនិងរដ្ឋ និង ទទួលឥទ្ធិពលពីឧក្រិដ្ឋកម្មប្រឆាំងស្ត្រី ដែលត្រូវបានប្រព្រឹត្តនៅក្នុងប្រទេស បូស្នៀ និង Herzegovina ដែលមានលក្ខណៈខុសគ្នាពីការប្រព្រឹត្តិ ដែលកើតមានឡើងនៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ[32]។

25. ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងផ្ទុយពីនេះថា ត្រឹមឆ្នាំ ១៩៧៥ អំពើដែលហាមឃាត់នោះគឺ“*ការបង្កឱ្យស្ត្រី ឬ ក្មេងស្រីណាម្នាក់មានផ្ទៃពោះដោយបង្ខំ ប្រឆាំងនឹងឆន្ទៈរបស់គាត់ ឬ ស្ថិតក្រោមកាលៈទេសៈបង្ខិតបង្ខំ*”[33]។ សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា អំពើនោះរំលោភបំពានលើសិទ្ធិនិងតម្លៃដាច់ខាត ដូចជា សេចក្តីថ្លៃថ្នូររបស់មនុស្ស ស្វ័យភាព សមភាព ជម្រើសក្នុងការបន្តពូជ និង ឈានដល់កម្រិតដែលអាចបង្កើតបានជាបទល្មើសមួយនៃ“អំពើអមនុស្សធម៌ផ្សេងៗទៀត”[34]។

---

[28] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ១៧, ២០។

[29] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ២៣។

[30] សំណើសហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ២, ១៥។

[31] សំណើសហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៣, ៦, ៩។

[32] សំណើសហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៧-៨។

[33] សំណើសហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៣, ១១។

[34] សំណើសហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១០។

01330285



26. សហព្រះរាជអាជ្ញាអន្តរជាតិបែងចែកដាច់ពីគ្នា ចំពោះអំពើដែលកើតចេញពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង ការរំលោភសេពសន្ថវៈ ដោយផ្អែកលើមូលដ្ឋានដែលថា ការមានផ្ទៃពោះដោយបង្ខំអាចកើតមាននៅក្រៅវង្វង់នៃបរិបទនៃ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬ ការរំលោភសេពសន្ថវៈ និងដែលបណ្ដាលឱ្យមានព្យសនកម្មយូរអង្វែង ខុសពីការរៀបអាពាហ៍ពិពាហ៍ និង ការរំលោភសេពសន្ថវៈដោយបង្ខំ ដែលការប្រែប្រួលរាងកាយរបស់ជនរងគ្រោះងាយមើលឃើញ និង ច្បាស់លាស់ ជនរងគ្រោះត្រូវបង្កើតកូន និង ថែរក្សាកូនដែលខ្លួនមិនចង់បាននោះ ជនរងគ្រោះត្រូវនឹកឃើញជាប្រចាំថាកូននោះជាលទ្ធផលនៃការរំលោភលើរាងកាយ និង ភាពជាជនរងគ្រោះ ហើយប្រហែលជាត្រូវស៊ូទ្រាំនឹងស្លាកស្នាមទុរយសសង្គមជាមួយនឹងកូន[35]។

27. សហព្រះរាជអាជ្ញាអន្តរជាតិ កំណត់បញ្ហាជាក់លាក់សម្រាប់ឱ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងការបង្កឱ្យមានផ្ទៃពោះដោយបង្ខំ[36]។ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថាជាការល្អបំផុតគេត្រូវកំណត់បទចោទបានត្រឹមត្រូវ នៅពេលបិទបញ្ចប់កិច្ចស៊ើបសួរ[37] ប៉ុន្តែ សហព្រះរាជអាជ្ញាអន្តរជាតិគិតទុកជាមុនថាភស្តុតាងដែលទទួលបាន នឹងត្រូវបង្ហាញថា ការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងទម្រង់“អំពើអមនុស្សធម៌ផ្សេងៗទៀត”បានកើតឡើង ឬ ព្យសនកម្មដែលបានរងគ្រោះដោយជនរងគ្រោះពីការរៀបអាពាហ៍ ពិពាហ៍ដោយបង្ខំ និង ការរំលោភសេពសន្ថវៈក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[38]។

## ឃ) ការឆ្លើយតបរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

28. មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអះអាងថា សំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមិនមែនដាក់មិនត្រឹមត្រូវតាមពេលវេលានោះទេ ដោយសារការស៊ើបអង្កេតក្នុងករណី អោ អាន និង យឹម ទិត្យ កំពុងធ្វើបន្ត និង គ្មានរយៈពេលកំណត់ណាមួយ ដាក់កំហិតលើការដាក់សំណើសុំកិច្ចស៊ើបសួរអនុលោមតាមវិធាន ៥៥(១) នៃវិធានផ្ទៃក្នុង[39]។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើងថាទោះជាក្នុងកាលៈទេសៈណាក៏ដោយ សិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបានការជំនុំជម្រះដោយឆាប់

[35] សំណើសហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១១-១២។

[36] សំណើសហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១៣។

[37] សំណើសហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ១៤។

[38] *ដូចខាងលើ*។

[39] ចម្លើយតបរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី កថាខណ្ឌ ១១។



Original EN: 01251580-01251604

របស់ មិនមែនជាសិទ្ធិដាច់ខាតនោះទេ និង ត្រូវថ្លឹងថ្លែងឲ្យមានតុល្យភាពគ្នាជាមួយសិទ្ធិរបស់ជនរងគ្រោះក្នុងការស្វែងរកការពិត[40]។

29. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា សំណើរបស់ខ្លួនមិនចាំបាច់បង្ហាញមូលហេតុបឋមដើម្បីឲ្យសហចៅក្រមស៊ើបអង្កេតជឿថា ព័ត៌មានដែលខ្លួនបានស្នើ អាចជាភស្តុតាងដោះបន្ទុកនោះទេ[41]។

30. ស្របពេលដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គាំទ្រសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និង បញ្ជានៃការស៊ើបអង្កេតដូចដែលបានស្នើដោយសហព្រះរាជអាជ្ញាអន្តរជាតិ[42] មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនបានបកស្រាយពាក់ព័ន្ធនឹងការជំទាស់របស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីភាពមិនសមស្របក្នុងការអនុវត្តនិយមន័យនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៃលក្ខន្តិកៈទីក្រុងរ៉ូម នៅក្នុង អ.វ.ត.ក។

## III. ការពិភាក្សា

31. សំណើទាំងពីររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង សហព្រះរាជអាជ្ញាអន្តរជាតិ បរាជ័យក្នុងហេតុផលបីធំៗ៖

ក) គ្មាននិយមន័យរួមមួយ ស្តីពីការមានផ្ទៃពោះដោយបង្ខំ នៅក្នុងច្បាប់កម្ពុជា និង ច្បាប់អន្តរជាតិនៅចន្លោះឆ្នាំ ១៩៧៥ និង ១៩៧៩ និង គ្មានបទដ្ឋានសិទ្ធិមនុស្សច្បាស់លាស់ ដែលភ្ជាប់ទៅនឹងអំពើដែលបង្កើតបានជាការមានផ្ទៃពោះដោយបង្ខំ ដែលការរំលោភបំពាន អាចឈានទៅរកការប្រព្រឹត្តិបទល្មើសមួយនៃទម្រង់“អំពើអមនុស្សធម៌ផ្សេងៗទៀត”។ ចំណុចនេះអនុវត្តបានដូចគ្នាចំពោះគោលការណ៍ *a maiore ad minus* ពាក់ព័ន្ធនឹងការបង្កឲ្យមានផ្ទៃពោះដោយបង្ខំ។ ដូច្នេះ ការស៊ើបអង្កេតត្រូវហាមឃាត់ដោយគោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង*។ និយមន័យនៃច្បាប់ជាធរមាន ត្រូវតែបង្កើតឡើងនៅមុនមានសេចក្តីសម្រេចក្នុងការស៊ើបអង្កេត និង មិនអាចទុករហូតដល់ចុងបញ្ចប់នៃការស៊ើបអង្កេតនោះទេ។

---

[40] ចម្លើយតបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១២។

[41] ចម្លើយតបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៦។

[42] ចម្លើយតបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៨។

ខ) បន្ទាប់ពីការស៊ើបអង្កេតអស់រយៈពេលច្រើនឆ្នាំ បច្ចុប្បន្ននេះពុំមានភស្តុតាង ដែលគាំទ្រដល់គោលនយោបាយនៃការបង្កឲ្យមានផ្ទៃពោះដោយបង្ខំ ឬ ការមានផ្ទៃពោះដោយបង្ខំ ទោះបីគេចង់អនុវត្តទ្រឹស្តីនេះ ដូចមានចែងនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមក៏ដោយ។

គ) ជាចុងក្រោយ ទោះបីជាមាននិយមន័យបែបនេះ ដែលអាចអនុវត្តបានចំពោះយុត្តាធិការនៃពេលវេលារបស់ អ.វ.ត.ក យ៉ាងណាក្តី សំណើទាំងពីរត្រូវបានដាក់យឺតពេកនៅក្នុងថ្ងៃដែលដាក់សំណើនោះ ដោយគ្មានបង្ហាញមូលហេតុសមស្រប។ ដូច្នេះ ការពង្រីកការស៊ើបអង្កេតឥឡូវនេះ នឹងនាំឲ្យមានបន្ទុកមិនចាំបាច់មួយលើមេធាវីការពារក្តី និង បណ្តាលឲ្យការពន្យារពេលដែលមិនអាចទទួលយកបាន នៅក្នុងការស៊ើបអង្កេត ដែលកំពុងស្ថិតក្នុងដំណាក់កាលវិវឌ្ឍបានយ៉ាងល្អរួចហើយ។

**ង) បទដ្ឋានសម្រាប់សំណើសុំកិច្ចស៊ើបសួរ**

32. ខុសពីសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានផ្តោតច្បាស់លាស់ថាជាសំណើសុំកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៥៥(១) នៃវិធានផ្ទៃក្នុងនោះទេ។ ប៉ុន្តែ ជាខ្លឹមសារបង្ហាញឲ្យឃើញច្បាស់ថាជាទម្រង់មួយនៃសំណើ ដោយសារមានការស្នើសុំដំណោះស្រាយមួយក្នុងនោះ។ ដូច្នេះ យើងពិនិត្យសំណើនេះជាមួយសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅតាមបទដ្ឋាននៃសំណើសុំកិច្ចស៊ើបសួរ ដែលធ្វើឡើងតាមវិធាន ៥៥(១)។

33. សំណើសុំកិច្ចស៊ើបសួរត្រូវ (i) កំណត់បង្ហាញអំពីសកម្មភាពដែលត្រូវធ្វើ ដោយមានការបញ្ជាក់ឲ្យបានច្បាស់លាស់គ្រប់គ្រាន់ និង (ii) បង្ហាញឲ្យបានពិស្តារអំពីមូលហេតុអ្វី បានជាសំណើបំពេញកិច្ចស៊ើបសួរដែលបានស្នើសុំ ពាក់ព័ន្ធជាបឋមទៅនឹងការបញ្ជាក់នូវការពិត[43]។ ផ្ទុយទៅនឹងការជំទាស់របស់មេធាវីការពារក្តី យឹម ទិត្យ ដែលថាគេមិនបាច់តម្រូវឲ្យសំណើត្រូវតែបញ្ជាក់មូលហេតុបឋមថាហេតុអ្វីបានជាកិច្ចស៊ើបសួរ នឹងផ្តល់ព័ត៌មានដោះបន្ទុក សម្អាងច្បាប់ដែលមេធាវីការពារក្តី យឹម ទិត្យ ដកស្រង់ដើម្បីគាំទ្រការជំទាស់នោះ មានលក្ខណៈជាក់លាក់ពាក់ព័ន្ធទៅនឹងសំណើរបស់មេធាវីការពារក្តី

---

[43] សំណុំរឿងលេខ 002-D365/2/17, *សាលដីកាស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង*, ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ៤៧។ សំណុំរឿងលេខ 002-D353/2/3, *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង"ដីកាស្តីពីសំណើសុំបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ" នៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១០,* ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០, កថាខណ្ឌ ៣៨។

ក្នុងសំណុំរឿង ០០៣ ដែលបានស្នើសុំកិច្ចស៊ើបសួរ ដែលអាចផ្តល់ភ័ស្តុតាងដោះបន្ទុក និង មិនបានបង្កើតជាលក្ខណៈវិនិច្ឆ័យទីបីសម្រាប់សំណើសុំកិច្ចស៊ើបសួរទាំងឡាយផ្សេងពីនេះ[44]។

34. សហចៅក្រមស៊ើបអង្កេត មានឆន្ទានុសិទ្ធិទូលំទូលាយក្នុងការសម្រេចលើភាពមានប្រយោជន៍ ឬ ឱកាសក្នុងការចាត់កិច្ចស៊ើបសួរ ដែលភាគីណាមួយស្នើសុំផងដែរ[45]។ ពេលអនុវត្តឆន្ទានុសិទ្ធិនោះ សហចៅក្រមស៊ើបអង្កេតត្រូវពិចារណាលើផលប៉ះពាល់លើភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ប្រសិនបើយល់ស្របតាមសំណើណាមួយនោះ[46]។ ពាក់ព័ន្ធនឹងការវាយតម្លៃនោះ គឺសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនត្រូវចោទ ជាពិសេសសិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាសមស្រប និង សិទ្ធិមានពេលវេលាគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការការពារក្តីរបស់ខ្លួន ដែលសិទ្ធិទាំងពីរនេះជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលធានាដោយលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ និងនៅចំពោះមុខ អ.វ.ត.ក[47]។

---

[44] នៅក្នុង *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង"ដីកាស្តីពីសំណើសុំបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ* ដែលបានដកស្រង់ដោយមេធាវីការពារក្តី យឹម ទិត្យ, អង្គបុរេជំនុំជម្រះបានបញ្ជាក់អំពីបទដ្ឋានភ័ស្តុតាងដែលពាក់ព័ន្ធជាបឋម សម្រាប់សំណើសុំបំពេញកិច្ចស៊ើបសួរ និង បញ្ជាក់បន្ថែមទៀតថា បទដ្ឋាននេះអនុវត្តបានផងដែរចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរ ដែលនឹងនាំទៅរកភ័ស្តុតាងដោះបន្ទុក (សំណុំរឿងលេខ 002-D353/2/3, ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៣៨, ៤៧)។

[45] សំណុំរឿងលេខ 002-D365/2/17, *សាលដីកាលើការពិចារណាឡើងវិញអំពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំដាក់ឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង*, ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ ៣៦។ សំណុំរឿងលេខ 002-D164/4/13, *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភ័ស្តុតាងដោះបន្ទុកនៅឃ្លាំងផ្ទុកឯកសាររួម*, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩, កថាខណ្ឌ ២២, ២៥។

[46] សំណុំរឿងលេខ 002-D365/2/17, *សាលដីកាលើការពិចារណាឡើងវិញអំពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំដាក់ឯកសារភ័ស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង*, ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ ៤៧។

[47] ច្បាប់ អ.វ.ត.ក, មាត្រា ៣៣ថ្មី បញ្ចូលមាត្រា ១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាជាប្រទេសហត្ថលេខី។ មាត្រា ១៤(៣) នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយចែងថា "*ក្នុងការសម្រេចសេចក្តីអំពីការចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើគាត់ ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ* (...) *(គ) ត្រូវបានជំនុំជម្រះដោយឥតពន្យារពេលយូរហួស* (...)"។ *សូមមើលផងដែរ* វិធាន ២១ ដែលមានចែងបញ្ញត្តិស្រដៀងគ្នានេះ។

35. សិទ្ធិទាំងនេះអនុវត្តស្មើគ្នានៅក្នុងដំណាក់កាលមុនអង្គសេចក្តី[48]។ ដើម្បីសម្រេចគោលបំណងនៃការវាយតម្លៃលើពេលវេលាសមស្របនៃកិច្ចដំណើការនីតិវិធីព្រហ្មទណ្ឌ យើងយល់ឃើញថាយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបមានលក្ខណៈសមស្រប ដោយកំណត់ពេលវេលាគិតចាប់ពីពេលដែល "*សេចក្តីជូនដំណឹងជាផ្លូវការ ត្រូវបានជូនដល់បុគ្គលណាមួយ តាមរយៈអាជ្ញាធរមានសមត្ថកិច្ច អំពីការចោទប្រកាន់ដែលបុគ្គលនោះបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ*"[49]។

36. ស៊ីគ្នាទៅនឹងគោលការណ៍ខាងលើ អង្គបុរេជំនុំជម្រះធ្លាប់បានពិចារណាលើការពន្យារពេលនីតិវិធីដោយឥតចាំបាច់ នៅពេលសម្រេចលើបណ្តឹងសាទុក្ខនៃដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំកិច្ចស៊ើបសួរ[50]។ អង្គបុរេជំនុំជម្រះក៏បានគូសបញ្ជាក់ផងដែរថា "*ឱកាសក្នុងការដាក់សំណើណាមួយ អនុលោមតាមវិធាន ៥៥(១) គឺអាស្រ័យលើការបំពេញករណីយកិច្ចទូទៅរបស់ភាគីសំណើ ក្នុងការ'ដាក់សំណើដែលមានលក្ខណៈមួយ មិនធ្វើឱ្យពន្យារពេលនីតិវិធី'*"[51]។ យើងយល់

---

[48] សំណុំរឿងលេខ 002-D264/2/6, *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើសុំផ្អាកកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធី (D264/1)*, ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០ កថាខណ្ឌ ១៣។

[49] តុលាការសិទ្ធិមនុស្សអឺរ៉ុប, *Deweer ទល់នឹង ប្រទេសប៊ែលហ្ស៊ិក*, ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៨០ កថាខណ្ឌ ៤៦។ និយមន័យដែលស្របគ្នាទៅនឹងការធ្វើតេស្តរកមើល ថាតើស្ថានភាពនៃជនសង្ស័យត្រូវបាន"*រងផលប៉ះពាល់ខ្លាំង*" ដែរឬយ៉ាងណា។ តុលាការសិទ្ធិមនុស្សអឺរ៉ុប, *Neumeister ទល់នឹង ប្រទេសអូទ្រីស*, ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៦៨, "ទឡ្ហីករណ៍របស់គណកម្មការ និង រដ្ឋាភិបាល", កថាខណ្ឌ ១៣។ តុលាការសិទ្ធិមនុស្សអឺរ៉ុប, *Eckle ទល់នឹង ប្រទេសអាល្លឺម៉ង់*, ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៨២, កថាខណ្ឌ ៧៣។ តុលាការសិទ្ធិមនុស្សអឺរ៉ុប, *McFarlane ទល់នឹង ប្រទេសអៀរឡង់*, ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ ១៤៣)។

[50] *សូមមើលសំណុំរឿងលេខ* 002-D315/1/5, *សាលដីកាលើបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចចំពោះសំណើរបស់ នួន ជា សុំឱ្យមានកិច្ចស៊ើបសួរទាក់ទងនឹងទំនាក់ទំនងរដ្ឋបរទេស និង សាលដីលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចទាក់ទងនឹងសំណើសុំបើកកិច្ចស៊ើបសួរទាក់ទងនឹងរដ្ឋបរទេស ចំពោះការទាត់ចោលសំណើសុំស្តាប់ចម្លើយសាក្សីដែលធ្វើឡើងដោយ ខៀវ សំផន*, ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ២២។ សំណុំរឿងលេខ 002-D365/2/17, *សាលដីកាលើការពិចារណាឡើងវិញអំពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំដាក់ឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង*, ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ ៥៣-៥៤។

[51] សំណុំរឿងលេខ 002-D365/2/17, *សាលដីកាលើការពិចារណាឡើងវិញអំពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំដាក់ឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង*, ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ ៥៣។

ឃើញថា នេះជាការបញ្ជាក់អំពីលក្ខខណ្ឌតម្រូវ ដែលភាគីត្រូវបំពេញដោយមានការយកចិត្តទុកដាក់ត្រឹមត្រូវ នៅពេលស្នើសុំចូលរួមក្នុងកិច្ចស៊ើបសួរ តាមយន្តការវិធាន ៥៥(១០)។

37. យើងយល់ឃើញថា សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សមស្របដោយសារបានកំណត់កិច្ចស៊ើបសួរដែលបានស្នើសុំ ដោយមានការបញ្ជាក់ច្បាស់លាស់គ្រប់ និង សំណួរដែលត្រូវសួរសាក្សីពាក់ព័ន្ធនឹងការមានផ្ទៃពោះដោយបង្ខំ និង ការបង្កឱ្យមានផ្ទៃពោះដោយបង្ខំ។ យើងយល់ឃើញផងដែរថា សំណើទាំងពីរមានលក្ខណៈសមស្រប ដោយសារតែបានកំណត់អំពីមូលហេតុអ្វីបានជាកិច្ចស៊ើបសួរដែលបានស្នើឡើងនោះ មានភាពពាក់ព័ន្ធជាបឋមទៅនឹងការបញ្ជាក់ការពិត។

38. ទោះជាយ៉ាងនេះក្តី ដូចមានពន្យល់ពិស្តារនៅខាងក្រោម យើងបដិសេធសំណើទាំងពីរដោយសម្អាងលើ (i) សំណើទាំងពីរមិនបានបំពេញគោលការណ៍នីត្យានុកូល (ii) សំណើទាំងពីរដាក់មិនត្រឹមត្រូវតាមពេលវេលា ដែលបង្ហាញឱ្យឃើញពីភាពខ្វះការយកចិត្តទុកដាក់ត្រឹមត្រូវ (iii) ប្រសិនបើយើងយល់ស្របតាមសំណើទាំងពីរ នោះនឹងនាំឱ្យមានការពន្យារពេលដោយមិនចាំបាច់ដល់កិច្ចដំណើរការនីតិវិធី និង (iv) កិច្ចស៊ើបសួរដែលបានស្នើសុំ មិនទំនងនឹងបានផ្តែផ្តាអ្វីទេ ដោយសារតែភស្តុតាងដែលមាននៅក្នុងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ រហូតមកដល់ពេលបច្ចុប្បន្ននេះ មិនគាំទ្រការចោទប្រកាន់អំពីបទមានផ្ទៃពោះដោយបង្ខំ និង ការបង្កឱ្យមានផ្ទៃពោះដោយបង្ខំនោះទេ។

### ច) នីត្យានុកូលភាពនៃការមានផ្ទៃពោះដោយបង្ខំ ក្នុងទម្រង់មួយនៃ"អំពើអមនុស្សធម៌ផ្សេងៗទៀត" ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩

39. ការមានផ្ទៃពោះដោយបង្ខំ មិនមែនជាបទឧក្រិដ្ឋដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦[52] ដែលជាផ្លូវការនៅតែអាចអនុវត្តបានពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[53]។

40. ម្យ៉ាងវិញទៀត ការមានផ្ទៃពោះដោយបង្ខំមិនត្រូវបានកំណត់ជាបទឧក្រិដ្ឋ កុំថាដល់កំណត់និយមន័យក្នុងលិខិតុបករណ៍អន្តរជាតិ ដែលកំណត់ច្បាប់សង្គ្រាមត្រឹមឆ្នាំ ១៩៧៥។ លិខិតុបករណ៍ទាំងនេះ ផ្តល់

[52] ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ដែលបានកែសម្រួលបានកំណត់ក្នុងច្បាប់ ជាលើកដំបូងនូវឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដែលបញ្ចូលការមានផ្ទៃពោះដោយបង្ខំ ក្នុងចំណោមឧក្រិដ្ឋកម្មជាក់លាក់ដទៃទៀត ប៉ុន្តែ មិនបានចែងកំណត់និយមន័យនៃការមានផ្ទៃពោះដោយបង្ខំទេ។ *សូមមើល* មាត្រា ១៨៨(៧) នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។

[53] សំណុំរឿងលេខ 001-E188, *សាលាក្រម*, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ២៩។

ការការពារធំទូលាយដល់បុគ្គល ដើម្បីប្រឆាំងនឹងអំពើហិង្សា សម្រាប់កិត្តិយស និង សិទ្ធិរបស់គ្រួសាររបស់ពួកគាត់ និង សម្រាប់ការការពារស្ត្រីពីការរំលោភសេពសន្ថវៈ។

41. ក្រម Lieber Code ឆ្នាំ ១៨៦៣ បានដាក់ការរំលោភសេពសន្ថវៈលើជននៅក្នុងប្រទេសដែលត្រូវបានគេឈ្លានពាន ថាជាបទល្មើសព្រហ្មទណ្ឌ និង ចែងដើម្បីការពារ"*ជនដែលជាអ្នកភូមិ ជាពិសេសស្ត្រី និង ភាពពិសិដ្ឋនៃទំនាក់ទំនងគ្រួសារ*"[54]។ អនុសញ្ញាក្រុងឡាអេឆ្នាំ ១៨៩៩ និង ឆ្នាំ ១៩០៧ សុទ្ធតែមិនបានចែងអំពីបញ្ញត្តិណាមួយពាក់ព័ន្ធនឹងសុចរិតភាពផ្នែករាងកាយរបស់ស្ត្រី[55]។ ធម្មនុញ្ញរបស់សាលាក្ដីតូក្យូ និង Nuremberg ក៏មិនបានចែងថាដាក់ឱ្យទៅជាបទល្មើសព្រហ្មទណ្ឌច្បាស់លាស់នោះដែរ ចំពោះអំពើហឹង្សាប្រឆាំងស្ត្រី[56]។

42. អនុសញ្ញាក្រុងហ្សឺណែវ IV ឆ្នាំ ១៩៤៩ បញ្ជាក់បន្ថែមអំពីការការពារជាក់លាក់សម្រាប់ស្ត្រី ប្រឆាំងនឹងហឹង្សាក្នុងជម្លោះប្រដាប់អាវុធ ដោយចែង"ជនដែលត្រូវបានការពារ" ត្រូវមានសិទ្ធិទទួលបាន "*ការគោរពចំពោះភាពជាបុគ្គលរបស់ពួកគាត់ កិត្តិយសរបស់ពួកគាត់ សិទ្ធិរបស់ក្រុមគ្រួសាររបស់ពួកគាត់ ការគោរព និង ប្រតិបត្តិសាសនារបស់ពួកគាត់ និង ឬកពា និង ទំនៀមទម្លាប់របស់ពួកគាត់។ ពួកគាត់មិនត្រូវរងការប្រព្រឹត្តបែបអមនុស្សធម៌ ទោះក្នុងកាលៈទេសៈណាក៏ដោយ និង ត្រូវទទួលបានការការពារ ជាពិសេសប្រឆាំងរាល់អំពើហឹង្សានៃការគំរាមកំហែង និង ប្រឆាំងការប្រមាថ និង ភាពចង់ដឹងពីសំណាក់សាធារណជន។ ស្ត្រីត្រូវទទួលបានការការពារជាពិសេស ប្រឆាំងរាល់ការវាយប្រហារណាមួយលើកិត្តិយសរបស់ពួកគាត់ ជាពិសេសប្រឆាំងនឹងការពេស្យាចារដោយបង្ខំ ឬ ទម្រង់ណាមួយនៃការវាយប្រហារបែបមិនសមរម្យ*"[57]។

---

[54] មាត្រា ៣៧ និង ៤៤ នៃដីការួមលេខ 100៖ ក្រម Lieber Code – សេចក្ដីណែនាំសម្រាប់រដ្ឋាភិបាលរបស់កងទ័ពសហរដ្ឋអាមេរិកនៅ Field។

[55] នៅក្នុងបរិបទនៃការកំណត់សមត្ថកិច្ចយោធាលើដែនដីនៃរដ្ឋបច្ចាមិត្រ អនុសញ្ញាទីក្រុងឡាអេ គ្រាន់តែតម្រូវឱ្យគោរព"កិត្តិយស និង សិទ្ធិរបស់គ្រួសារ" (មាត្រា ៤៦ នៃបញ្ញត្តិពាក់ព័ន្ធនឹងច្បាប់ និង ទំនៀមទម្លាប់សង្គ្រាមនៅលើដី ដែលជាឧបសម្ព័ន្ធភ្ជាប់ទៅនឹងអនុសញ្ញា (II) និង (IV) ពាក់ព័ន្ធនឹងច្បាប់ និង ទំនៀមទម្លាប់សង្គ្រាមលើដី, ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៨៩៩ និង ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩០៧)។

[56] *សូមមើល* មាត្រា ៦ នៃធម្មនុញ្ញរបស់សាលាក្ដីយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ដែលបានរាយនាមឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថាជាឧក្រិដ្ឋកម្មស្ថិតក្នុងយុត្តាធិការរបស់សាលាក្ដី Nuremberg និង តូក្យូ។ បញ្ញត្តិពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានបញ្ចូលតែ"*ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការបណ្ដេញចេញ និង អំពើអមនុស្សធម៌ផ្សេងៗទៀត...*"។

[57] អនុសញ្ញាទីក្រុងហ្សឺណែវ IV, មាត្រា ២៧។

43. ពិធីសារបន្ថែមឆ្នាំ ១៩៧៧ ចែងច្បាស់អំពីការហាមឃាត់អំពើសេពសន្ថវៈ អំពើពេស្យាចារដោយបង្ខំ ឬ ទម្រង់ដទៃទៀតនៃការវាយប្រហារមិនសមរម្យប្រឆាំងស្ត្រី[58]។ មិនតែប៉ុណ្ណោះ ពិធីសារនោះ បានហាមឃាត់អំពើហឹង្សាលើជីវិត សុខភាព ឬ សុខុមាលភាពរាងកាយ និង ផ្លូវចិត្តរបស់មនុស្ស ជាពិសេស អំពើមនុស្សឃាត អំពើទារុណ្ណកម្មគ្រប់ទម្រង់ (មិនថាផ្លូវកាយ ឬ ផ្លូវចិត្ត), ទុរណ្ណកម្មលើរាងកាយ, និង ការកាត់ឬចោះ និង ភាពព្រៃផ្សៃលើសេចក្តីថ្លៃថ្នូររបស់មនុស្ស[59]។

44. ការមានផ្ទៃពោះដោយបង្ខំ ត្រូវបានកំណត់ជាច្បាប់ និង កំណត់និយមន័យថាជាបទឧក្រិដ្ឋមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងមាត្រា ៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម[60]។ ក្នុងមាត្រានោះ ការមានផ្ទៃពោះដោយបង្ខំ ត្រូវបានកំណត់និយមន័យថាជា "*ការបង្ខាំងស្ត្រីណាម្នាក់ដោយខុសច្បាប់ និង បង្ខំឱ្យមានផ្ទៃពោះ ដោយមានចេតនាធ្វើឱ្យប៉ះពាល់ដល់សមាភាពនៃជាតិពន្ធុនៃជាតិសាសន៍ ឬ ការប្រព្រឹត្តិការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់អន្តរជាតិដទៃទៀត*"[61]។ លក្ខន្តិកៈទីក្រុងរ៉ូមបន្ថែមថា "*ទោះតាមមធ្យោបាយណាក៏ដោយ និយមន័យនេះមិនត្រូវបកស្រាយ ឲ្យមានឥទ្ធិពលលើច្បាប់ជាតិពាក់ព័ន្ធនឹងការមានផ្ទៃពោះ*"[62]។

---

[58] មាត្រា ៤(២)(ង) នៃពិធីសារបន្ថែមនៃអនុសញ្ញាទីក្រុងហ្សឺណែវថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និង ពាក់ព័ន្ធនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៧៧ ចែងច្បាស់លាស់ហាមឃាត់ការរំលោភសេពសន្ថវៈ នៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ។ មាត្រា ៧៥(២) នៃពិធីសារបន្ថែមនៃអនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និង ពាក់ព័ន្ធនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ ហាមឃាត់ការប្រព្រឹត្តិបន្ទាបបន្ថោក ឬ ប្រមាថ ការបង្ខំឱ្យប្រព្រឹត្តពេស្យាចារ និង ទម្រង់នៃការវាយប្រហារមិនសមរម្យផ្សេងៗទៀត មិនថាប្រព្រឹត្តឡើងដោយជនស៊ីវិល ឬ ភ្នាក់ងារយោធានោះឡើយ។

[59] មាត្រា ៧៥ នៃពិធីសារបន្ថែមនៃអនុសញ្ញាទីក្រុងហ្សឺណែវថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និង ពាក់ព័ន្ធនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធអន្តរជាតិ។ មាត្រា ៤(២)(ក) នៃពិធីសារបន្ថែមនៃអនុសញ្ញាទីក្រុងហ្សឺណែវថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និង ពាក់ព័ន្ធនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៧៧។

[60] *សូមមើល* Kristen Boon, "ការរំលោភសេពសន្ថវៈ និង ការមានផ្ទៃពោះដោយបង្ខំនៅក្នុងលក្ខិន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ៖ សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ, ស្វ័យភាព និង ការយល់ព្រម", *ការពិនិត្យច្បាប់សិទ្ធិមនុស្សរបស់ប្រទេសកូឡុំប៊ី,* ៣២, ២០០០-២០០១, ទំព័រទី ៦៣០។ Soh Sie Eng Jessie, "ការមានផ្ទៃពោះដោយបង្ខំ៖ ការចែងជាច្បាប់នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម និង ទស្សនៈវិស័យអំពីអំពើប្រល័យពូជសាសន៍របស់វា", *ទស្សនាវត្តីប្រទេសណូវែលហ្សេឡង់ស្តីពីច្បាប់សាធារណៈអន្តរជាតិ*, ៤, ២០០៦, ទំព័រទី ៣១៩។

[61] មាត្រា ៧(២)(ច) នៃលក្ខន្តិកៈទីក្រុងរ៉ូម។

[62] *ដូចខាងលើ*។

45. ដូចគ្នានេះដែរ លក្ខន្តិកៈជាបន្តបន្ទាប់មកទៀតរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន និង ក្រុមប្រឹក្សាពិសេសប្រទេសទីម័រខាងកើតសម្រាប់បទឧក្រិដ្ឋធ្ងន់ធ្ងរ បានដាក់បញ្ចូលការមានផ្ទៃពោះដោយបង្ខំ ជាបទឧក្រិដ្ឋមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[63]។

i. <u>ក្របខ័ណ្ឌសម្រាប់វាយតម្លៃ"អំពើអមនុស្សធម៌ផ្សេងៗទៀត"</u>

46. ការដែលការមានផ្ទៃពោះដោយបង្ខំ មិនត្រូវបានដាក់ឲ្យទៅជាបទល្មើសឧក្រិដ្ឋឯករាជ្យដោយខ្លួនឯង ត្រឹមឆ្នាំ ១៩៧៥ មិនមែនបានន័យថាគេមិនអាចចាត់ទុកវាថាជាបទឧក្រិដ្ឋមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងទម្រង់នៃ"អំពើអមនុស្សធម៌ផ្សេងទៀត"នោះទេ ឲ្យតែលក្ខខណ្ឌនៃធាតុផ្សំត្រូវបានបំពេញ[64]។ ប្រភេទនៃ"អំពើអមនុស្សធម៌ផ្សេងៗទៀត"ត្រូវបានដាក់ឲ្យទៅជាបទឧក្រិដ្ឋរួចហើយ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥[65]។ ដូច្នេះ មិនចាំបាច់រកឲ្យឃើញថា អំពើជាក់លាក់នោះគឺជាបទឧក្រិដ្ឋមួយដោយខ្លួនឯងពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩[66]។ ចំណុចនេះមានភាពស៊ីសង្វាក់គ្នាទៅនឹងយុត្តិសាស្ត្ររបស់សាលាក្តីអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") និង តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន[67]។

---

[63] *សូមមើលមាត្រា* ២(ឆ) នៃលក្ខន្តិកៈរបស់កេរតំណែលនៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន និង ផ្នែក ៥.១(ឆ) នៃបញ្ញត្តិលេខ 2000/15 ស្តីពីការបង្កើតក្រុមប្រឹក្សាដែលមានយុត្តាធិការដាច់ខាតលើបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ។

[64] សំណុំរឿងលេខ 004-D257/1/8, *សេចក្តីពិចារណាលើសំណើ អោ អាន សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ,* យោបល់ស្តីពីមូលភាពនៃពាក្យសុំរបស់ចៅក្រម Baik និង Beauvallet, ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦ កថាខណ្ឌ ១០។

[65] សំណុំរឿងលេខ 002-D427/2/15, *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធារិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១៥៦-១៥៧។ សំណុំរឿងលេខ 002-E313, *សាលក្រម*, ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៣៥-៤៣៦។ សំណុំរឿងលេខ 001-E188, *សាលក្រម*, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ៣៦៧។ សំណុំរឿងលេខ 004-D257/1/8, *សេចក្តីពិចារណាលើសំណើរបស់ អោ អាន សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ,* យោបល់ស្តីពីមូលភាពនៃពាក្យសុំរបស់ចៅក្រម Baik និង Beauvallet, ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦ កថាខណ្ឌ ៩។

[66] *ដូចខាងលើ*។

[67] *ព្រះរាជអាជ្ញា ទល់នឹង Blagojević និង Jokić*, សាលក្រម, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-02-60-T), ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥, កថាខណ្ឌ ៦២៤។ ព្រះរាជអាជ្ញា ទល់នឹង *Stakić*, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (IT-97-24-A), ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦, កថាខណ្ឌ ៣១៥។ *ព្រះរាជអាជ្ញា ទល់នឹង Brima & Others*, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (SCSL-2004-16-A), ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨, កថាខណ្ឌ ១៨៣។

47. ប្រភេទនៃ"អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលជាបទឧក្រិដ្ឋមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជនជាប់ចោទអាចប្រមើលមើលដឹងថាជាបទល្មើស និង អាចដឹងថាមានច្បាប់ចែង ដូច្នេះវាស្របតាមគោលការណ៍នីត្យានុកូលភាព[68]។ ដូច្នេះ មិនចាំបាច់ត្រូវកំណត់ថាតើអំពើដែល បង្កើតបានជាការមានផ្ទៃពោះដោយបង្ខំនោះ បង្កើតបានជា"អំពើមួយនៃអំពើអមនុស្សធម៌ផ្សេងទៀត"នោះទេ។

48. អង្គជំនុំជម្រះសាលាដំបូងបានកំណត់ធាតុផ្សំនៃ"អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលចូលជាធរមានក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥៖

ក) អំពើសកម្ម ឬ អកម្មរបស់ចារី ដែលបណ្តាលឲ្យមានព្យសនកម្មលើរាងកាយ ឬ ផ្លូវចិត្តធ្ងន់ធ្ងរ ឬ ដែលបង្កើតបានជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។ ផលប៉ះពាល់នៃការឈឺចាប់ មិនបាច់ត្រូវតែមានរយៈពេលយូរអង្វែង ទោះបីប្រការនេះអាចពាក់ព័ន្ធនឹងកត្តាសម្រាប់កំណត់អំពីភាពធ្ងន់ធ្ងរនៃអំពើនោះក៏ដោយ[69]។

ខ) ចារីត្រូវតែប្រព្រឹត្តអំពើសកម្ម ឬ អកម្ម ដោយមានចេតនាបង្កការឈឺចាប់យ៉ាងធ្ងន់ធ្ងរ មកលើរូបរាងកាយ ឬ ផ្លូវចិត្ត ឬ ប្រព្រឹត្តអំពើហឹង្សាយ៉ាងធ្ងន់ធ្ងរ មកលើជនរងគ្រោះដែលធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្សជាតិ នៅពេលដែលបានប្រព្រឹត្តអំពើសកម្ម ឬ អកម្មនោះ[70] និង

គ) អំពើសកម្ម ឬ អកម្មត្រូវតែមានលក្ខណៈ និង ស្ថានទម្ងន់ស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាក់លាក់ផ្សេងទៀត អនុលោមតាមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ដែលត្រូវវាយតម្លៃដោយផ្អែកតាមករណីនីមួយៗ ដោយពិចារណាលើកាលៈទេសៈរបស់បុគ្គលនីមួយៗនៅក្នុងរឿងក្តី[71]។ កាលៈទេសៈទាំងនោះអាចរួមបញ្ចូលទាំងស្ថានភាពនៃអំពើសកម្ម ឬ អកម្ម បរិបទដែលបទឧក្រិដ្ឋកើតឡើង កាលៈទេសៈបុគ្គលរបស់ជនរងគ្រោះ (អាយុ ភេទ សុខភាព ។ល។) និង ផលវិបាកទៅលើរាងកាយ ផ្លូវចិត្ត និង សីលធម៌របស់ជនរងគ្រោះ[72]។

---

[68] សំណុំរឿងលេខ 002-E313 *សាលក្រម*, ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ៤៣៥-៤៣៦។

[69] សំណុំរឿងលេខ 002-E313 *សាលក្រម*, ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ៤៣៩។ សំណុំរឿងលេខ 001-E188, *សាលក្រម*, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ៣៦៩។

[70] សំណុំរឿងលេខ 002-E313 *សាលក្រម*, ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ៤៣៧។ សំណុំរឿងលេខ 001-E188, *សាលក្រម*, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ៣៦៨, ៣៧១។

[71] សំណុំរឿងលេខ 002-E313 *សាលក្រម*, ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ៤៣៨។ សំណុំរឿងលេខ 001-E188, *សាលក្រម*, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ៣៦៧-៣៦៩។

[72] សំណុំរឿងលេខ 001-E188, *សាលក្រម*, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ៣៦៩។

49. ដើម្បីកំណត់លក្ខណៈនៃការប្រព្រឹត្តិ និង ថាតើវាមានលក្ខណៈ និង ស្ថានទម្ងន់ស្រដៀងគ្នាទៅនឹងអំពើជាក់លាក់ដទៃទៀត និង យុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិដែលបង្ហាញថាតុលាការបានស្វះស្វែងកំណត់ព្រំដែនសម្រាប់ការប្រព្រឹត្តិ និង បន្ទាប់មកធ្វើការប្រៀបធៀបការប្រព្រឹត្តិនេះជាមួយនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និង/ឬ យុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិ ដើម្បីកំណត់ថាតើការប្រព្រឹត្តិនោះឈានដល់កម្រិតនៃ"អំពើអមនុស្សធម៌ផ្សេងទៀត"ដែរយ៉ាងណា។

50. កម្រិតនៃការត្រួតពិនិត្យនេះ ឆ្លុះបញ្ចាំងនូវមធ្យោបាយដែលសាលាក្តីអន្តរជាតិ និង សាលាក្តីចំពោះកិច្ចអនុវត្តដើម្បីធានាថា គោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង[73] មិនត្រូវបានរំលោភបំពាន។ ទ្រឹស្តីជាមូលដ្ឋាននៃគោលការណ៍នេះ មានបញ្ចូលភាពគ្មានអនុភាពប្រតិសកម្មនៃច្បាប់[74] និង លក្ខខណ្ឌតម្រូវក្នុងការបកស្រាយលក្ខន្តិកៈព្រហ្មទណ្ឌឲ្យបានតឹងរឹង ដើម្បីបានជាប្រយោជន៍ដល់ជនត្រូវចោទ[75]។ ជាឧទាហរណ៍ គោលការណ៍ទីពីរនោះ ត្រូវបានប្រើប្រាស់កាន់តែច្រើនឡើងនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ក្នុងមាត្រា ២២(២) ដែលចែងថា៖

"(២) និយមន័យនៃបទឧក្រិដ្ឋ ត្រូវតែបកស្រាយឲ្យបានតឹងរ៉ឹង និង មិនត្រូវបកស្រាយពន្លាតតាមន័យធៀបនោះទេ។ ក្នុងករណីដែលមានភាពមិនច្បាស់លាស់ ត្រូវបកស្រាយឲ្យបានជាប្រយោជន៍ដល់ជនដែលកំពុងស្ថិតក្រោមការស៊ើបអង្កេត ឬ ចោទប្រកាន់ ឬ ផ្តន្ទាទោស"។

51. ការកំណត់ព្រំដែនច្បាស់លាស់ សម្រាប់ការប្រព្រឹត្តិជាក់លាក់នោះក៏មានភាពចាំបាច់ផងដែរដើម្បីអាចកំណត់ថាតើ ជនត្រូវចោទនោះអាចប្រមើលមើលដឹង និង អាចដឹងថាមានបទមួយដែលអាចត្រូវគេស៊ើបអង្កេត និង ចោទប្រកាន់សម្រាប់ការប្រព្រឹត្តិជាក់លាក់ (លក្ខខណ្ឌតម្រូវជាមូលដ្ឋាននៃគោលការណ៍នីត្យានុកូលភាព)[76] ដែរឬយ៉ាងណា។ មធ្យោបាយនេះត្រូវបានយកមកអនុវត្តនៅតុលាការ ICTY,

---

[73] គោលការណ៍គ្មានបទល្មើបើគ្មានច្បាប់ចែង មានបញ្ជាក់ក្នុងមាត្រា ១៥ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដែលបញ្ចូលក្នុងនីតិវិធី អ.វ.ត.ក តាមរយៈមាត្រា ៣៣*ថ្មី* នៃច្បាប់ អ.វ.ត.ក។

[74] មាត្រា ៧ នៃ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ និង ត្រូវបានធ្វើបច្ចុប្បន្នភាពនៅក្នុងមាត្រា ៣ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩។

[75] *សូមមើល* មាត្រា ៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩។ សំណុំរឿងលេខ 002-E138, *សេចក្តីសម្រេចលើសម្បទាក្នុងការចូលរួមសវនាការរបស់ អៀង ធីរិទ្ធ*, ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១, កថាខណ្ឌ ៨០, ដកស្រង់ *ករណីព្រះរាជអាជ្ញា ទល់នឹង Delalić et al*, សាលក្រម, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-96-21-T), ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៤១៣។

[76] ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវនៃគោលការណ៍នីត្យានុកូលភាព ដែលអនុវត្តដោយអង្គជំនុំជម្រះសាលាដំបូង និង អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក។ សូមមើល៖ សំណុំរឿងលេខ 002-E313, *សាលក្រម*, ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤, កថា

តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន និង អ.វ.ត.ក ដូចមានបង្ហាញនៅក្នុងការវិភាគដូចខាងក្រោម។

ii. <u>ការវាយតម្លៃអំពី“អំពើអមនុស្សធម៌ផ្សេងៗទៀត” នៅតុលាការ ICTY</u>

52. អង្គជំនុំជម្រះនៃតុលាការ ICTY ក្នុងករណី *Kupreškić* បានពិចារណាយ៉ាងប្រយ័ត្នប្រយែងចំពោះវិសាលភាព និង អត្ថន័យនៃ“អំពើអមនុស្សធម៌ផ្សេងៗទៀត” ដោយសារតែក្តីបារម្ភចំពោះប្រការដែលថា ប្រភេទនៃបទឧក្រិដ្ឋនោះអាចមានលក្ខណៈទូទៅពេក ដែលមិនអាចបំពេញតាមលក្ខខណ្ឌនៃភាពច្បាស់លាស់នៃច្បាប់[77]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា គប្បីស្វែងរកក្នុងលក្ខន្តិកៈរបស់តុលាការ ICTY សម្រាប់កំណត់និយមន័យនៃ“អំពើអមនុស្សធម៌ផ្សេងៗទៀត”

> “ព្រំដែនដែលមានលក្ខណៈមិនសូវទូទៅពេក សម្រាប់ការបកស្រាយ“អំពើអមនុស្សធម៌ផ្សេងៗទៀត” អាចត្រូវបានកំណត់នៅក្នុងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមនុស្ស ដូចជាបទដ្ឋានដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សឆ្នាំ ១៩៤៨ និង អនុសញ្ញាចំនួនរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សឆ្នាំ ១៩៦៦។ ដោយពិចារណាលើបញ្ញត្តិពីមុនពាក់ព័ន្ធនឹងបរិបទទាំងនេះ គេអាចកំណត់សិទ្ធិមនុស្សជាមូលដ្ឋានមួយក្រុម ពាក់ព័ន្ធនឹងមនុស្សជាតិ ដែល, អាស្រ័យកាលៈទេសៈនៅពេលនោះ, ប្រសិនបើមានការរំលោភសិទ្ធិនេះនឹងនាំឲ្យកើតមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ...[អំពើនោះ]ត្រូវតែបានប្រព្រឹត្តជាលក្ខណៈប្រព័ន្ធ និង ជាទ្រង់ទ្រាយធំ។ ម្យ៉ាងវិញទៀត អំពើនោះត្រូវតែមានលក្ខណៈធ្ងន់ធ្ងរ ឲ្យដូចជាចំណាត់ថ្នាក់នៃបទឧក្រិដ្ឋផ្សេងៗទៀត ដែលមានចែងក្នុងបញ្ញត្តិដទៃទៀតនៃមាត្រា ៥។ កាលណាព្រំដែនគត្តិយុត្តសម្រាប់កំណត់ខ្លឹមសារគោលនៃប្រភេទ “អំពើអមនុស្សធម៌” ត្រូវបានកំណត់រួចហើយ នៅនឹងនាំគេអាចអនុវត្តវិធានដូចគ្នានេះសម្រាប់គោលបំណងក្នុងការប្រៀបធៀប និង វាយតម្លៃស្ថានទម្ងន់នៃអំពើដែលត្រូវបានហាមឃាត់នោះ”[78]។

---

ខណ្ឌ ១៦។ សំណុំរឿងលេខ 001-F28, *សាលដីកាបណ្តឹងឧទ្ធរណ៍*, ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ៩៦, ៩៧, ១៦០, ១៦២, ២១១, ២១២, ២៨០។

[77] *ព្រះរាជអាជ្ញា ទល់នឹង Kupreškić*, សាលក្រម, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-16-T), ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០, កថាខណ្ឌ ៥៦៣-៥៦៥។

[78] ដូចខាងលើ កថាខណ្ឌ ៥៦៦។

53. ការអនុវត្តវិធានដូចគ្នា *ejusdem generis*[79] នាំឲ្យអង្គជំនុំជម្រះក្នុងរឿងក្ដី *Kupreškić* សន្និដ្ឋានថា "*មានតែការបដិសេធដ៏ព្រៃផ្សៃ ឬ ជាក់ស្ដែងចំពោះសិទ្ធិមនុស្សជាមូលដ្ឋានប៉ុណ្ណោះ ដែលអាចបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*"[80]។ អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់បន្ថែមថា "*ទោះបីជាអំពើនីមួយៗអាចជាអំពើអមនុស្សធម៌ ផលវិបាករួមរបស់វាត្រូវតែមានសភាពប្រមាថដល់ភាពជាមនុស្សជាតិ ដែលឈានទៅដល់ការអាចកំណត់និយមន័យវាបានថាជា"អំពើអមនុស្សធម៌"។ ការដាក់កំហិតបែបនេះ ក៏មានលក្ខណៈគ្រប់គ្រាន់ក្នុងការបំពេញគោលការណ៍នីត្យានុកូលភាព ដោយសារអំពើអមនុស្សធម៌ ត្រូវបានហាមឃាត់យ៉ាងច្បាស់លាស់នៅក្នុងលក្ខន្តិកៈនោះ*"[81]។

54. ក្នុងរឿងក្ដី *Blagojević* អង្គជំនុំជម្រះសាលាដំបូងបានបន្ថែមថា គោលការណ៍នីត្យានុកូលភាពតម្រូវថា អំពើជាក់លាក់នោះត្រូវតែមានភាពដាច់ដោយឡែកពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាក់លាក់ផ្សេងៗទៀត[82]។

55. ក្នុងការអនុវត្តគោលការណ៍នេះ តុលាការ ICTY និង អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានរកឃើញថា ការប្រព្រឹត្តិនោះបង្កើតបានជា"អំពើអមនុស្សធម៌ផ្សេងៗទៀត" នៅក្នុងករណីដូចខាងក្រោម៖

---

[79] វិធានដូចគ្នា *ejusdem generis* ត្រូវបានកំណត់និយមន័យថាជា"*វិធានដែលប្រើសម្រាប់យល់ឯកសារច្បាប់ ដោយកំណត់ថា កាលណាមានពាក្យឬ ឃ្លាទូទៅ ដែលមានអមដោយឃ្លា ឬ ពាក្យជាក់លាក់ ពាក្យ ឬ ឃ្លាទូទៅនោះនឹងត្រូវបកស្រាយ ដើម្បីបញ្ចូលតែចំណុចដែលមានចំណាត់ថ្នាក់ដូចគ្នាតែប៉ុណ្ណោះ*" (វចនានុក្រម Black's Law Dictionary, 9th Ed.)។ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក បានគូសបញ្ជាក់ថា ការជ្រើសរើសប្រើប្រាស់វិធានដូចគ្នា *ejusdem generis* មិនរំលោភវិធានប្រឆាំងនឹងន័យធៀប ដែលមាននៅក្នុងយុត្តិសាស្ត្រច្បាប់ស៊ីវិលនោះឡើយ។ ការអនុវត្តបទឧក្រិដ្ឋដោយប្រើន័យធៀបចំពោះការប្រព្រឹត្តិដែលគ្មានចែងក្នុងបញ្ញត្តិ អាចខុសគ្នាពីការអនុវត្តប្រភេទទាបជាងនេះមួយ នៅក្នុងឧក្រិដ្ឋកម្ម (ធៀបនឹងអំពើអមនុស្សធម៌ផ្សេងៗទៀត) ទៅនឹងប្រភេទទាបជាងនេះមួយផ្សេងទៀតនៅក្នុងឧក្រិដ្ឋកម្មនោះ សម្រាប់បញ្ជាក់និយមន័យនៃប្រភេទដទៃមួយទៀតនោះ។ ដោយសារប្រភេទនៃ"អំពើអមនុស្សធម៌ផ្សេងៗទៀត" ត្រូវបានតាក់តែងធ្វើជាប្រភេទបន្ទាប់បន្សំ ដើម្បីចៀសវាងភាពចន្លោះប្រហោងនៅក្នុងច្បាប់ ពាក្យនេះគ្មានន័យទេ បើអនុវត្តគោលការណ៍នៃវិធានដូចគ្នា *ejusdem generis* ដែលប្រើសម្រាប់យល់ឯកសារច្បាប់ (សំណុំរឿងលេខ *សេចក្ដីពិចារណាលើសំណើ អោ អាន សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ,* យោបល់ស្ដីពីមូលភាពនៃពាក្យសុំរបស់ចៅក្រម Baik និង Beauvallet, ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦ លេខជើងទំព័រ ១៣០)។

[80] *ព្រះរាជអាជ្ញា ទល់នឹង Kupreškić*, សាលក្រម, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-16-T), ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០, កថាខណ្ឌ ៦២០។

[81] *ដូចខាងលើ* កថាខណ្ឌ ៦២២។

[82] *ព្រះរាជអាជ្ញា ទល់នឹង Blagojević និង Jokić*, សាលក្រម, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ (IT-02-60-T), ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥, កថាខណ្ឌ ៦២៤-៦២៥។

ក) ក្នុងករណីរបស់ *Blaskić* អង្គជំនុំជម្រះសាលាដំបូងពឹងផ្អែកលើយុត្តិសាស្ត្ររបស់សាលាក្តីអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា បញ្ញត្តិនៃលក្ខន្តិកៈទីក្រុងរ៉ូម និង សេចក្តីព្រាងក្រមបទឧក្រិដ្ឋប្រឆាំងសន្តិភាព និង សន្តិសុខមនុស្សជាតិរបស់គណកម្មការច្បាប់អន្តរជាតិ ដើម្បីរកឃើញថាការវាយប្រហារដែលបណ្តាលឲ្យមានរបួស ដែលខុសពីមនុស្សឃាត បង្កើតបានបទឧក្រិដ្ឋមួយនៃ"អំពើអមនុស្សធម៌ផ្សេងទៀត"[83]។

ខ) អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Krstić* បានយកសម្អាងហេតុក្នុងរឿងក្តី *Krajišnik*ជាសម្អាងផ្នែកច្បាប់ ដែលថាការផ្លាស់ប្តូរទីលំនៅដោយបង្ខំនៅក្នុង ឬ រវាងព្រំដែនជាតិ គឺជាអំពើអមនុស្សធម៌មួយ[84]។ ដើម្បីសម្រេចថាតើការប្រព្រឹត្តិនោះ បង្កើតបានជាការផ្លាស់ប្តូរទីលំនៅ ឬ ការបណ្តេញដោយបង្ខំ អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា កាលៈទេសៈដែលអនុញ្ញាតឲ្យជម្លៀសប្រជាជនអនុលោមតាមមាត្រា ៤៩ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV និង មាត្រា ១៧ នៃពិធីសារបន្ថែម II[85]។ អង្គជំនុំជម្រះរកឃើញថា នៅក្នុងកាលៈទេសៈនៃករណីនេះ ការផ្លាស់ប្តូរទីលំនៅប្រជាជនដោយបង្ខំ គឺបង្កើតបានជាទម្រង់មួយនៃការប្រព្រឹត្តិអមនុស្សធម៌[86]។

គ) ក្នុងករណី *Blagojević* ការហាមឃាត់ការផ្លាស់ប្តូរទីលំនៅដោយបង្ខំ បង្កើតបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង ដូច្នេះបំពេញគ្រប់លក្ខខណ្ឌដែលថា ការប្រព្រឹត្តនោះស្ថិតនៅក្នុងប្រភេទនៃអំពើអមនុស្សធម៌ផ្សេងៗទៀត[87]។

ឃ) ក្នុងករណី *Stakić* អង្គជំនុំជម្រះសាលាឧទ្ធរណ៍យោង និង ពឹងផ្អែកលើនិយមន័យ និង ធាតុផ្សំនៃការផ្លាស់ប្តូរទីលំនៅដោយបង្ខំនៅក្នុងយុត្តិសាស្ត្រពីមុនរបស់តុលាការ[88]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ដកស្រង់ការចោទលទោសអំពើទាំងនេះ នៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ IV ពិធីសារ

---

[83] *ព្រះរាជអាជ្ញា ទល់នឹង* Blaskić, សាលក្រម, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ (IT-95-14-T), ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០, កថាខណ្ឌ ២៣៨-២៣៩។

[84] *ព្រះរាជអាជ្ញា ទល់នឹង* Krstić, សាលក្រម, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ (IT-98-33-T), ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១, កថាខណ្ឌ ៥២៣។

[85] *ដូចខាងលើ* ថាខណ្ឌ ៥២៤។

[86] *ដូចខាងលើ* ថាខណ្ឌ ៥៣២។

[87] *ព្រះរាជអាជ្ញា ទល់នឹង* Blagojević *និង* Jokić, សាលក្រម, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ (IT-02-60-T), ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥, កថាខណ្ឌ ៦២៩។

[88] *ព្រះរាជអាជ្ញា ទល់នឹង* Stakić, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (IT-97-24-A), ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦, កថាខណ្ឌ ៣១៧។

បន្ថែម I និង សេចក្ដីព្រាងក្រមបទឧក្រិដ្ឋប្រឆាំងសន្តិភាព និង សន្តិសុខមនុស្សជាតិរបស់គណកម្ម ការច្បាប់អន្តរជាតិ សន្និដ្ឋានថា ការផ្លាស់ប្តូរទីលំនៅដោយបង្ខំត្រូវបានដាក់ឲ្យជាបទឧក្រិដ្ឋយ៉ាង ច្បាស់លាស់ នៅអំឡុងពេលនៃករណីនោះ និង ហេតុដូច្នេះ វារំលោភគោលការណ៍គ្មានបទល្មើស បើគ្មានច្បាប់ចែងនោះទេ[89]។ ដោយសារការប្រព្រឹត្តិនោះ ត្រូវបានរកឃើញផងដែរ ថាបង្កើតបាន ជា"អំពើអមនុស្សធម៌ផ្សេង"នៅក្នុងយុត្តិសាស្ត្រពីមុនរបស់តុលាការ ICTY អង្គជំនុំជម្រះសាលា ឧទ្ធរណ៍ពិចារណាឃើញថា អំពើនៃការផ្លាស់ប្តូរទីលំនៅដោយបង្ខំ អាចមានលក្ខណៈធ្ងន់ធ្ងរគ្រប់ គ្រាន់ ដែលបង្កើតបានជាអំពើអមនុស្សធម៌ផ្សេងៗទៀត[90]។ ការរកឃើញនេះ ត្រូវបានតម្កល់ដូច្នេះ បន្តទៅទៀត នៅក្នុងសាលក្រមក្រោយៗរបស់តុលាការ ICTY[91]។

iii. <u>ការវាយតម្លៃលើ"អំពើអមនុស្សធម៌ផ្សេងៗទៀត"នៅក្នុងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន</u>

56. ក្នុងរឿងក្តី *Brima* អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន គូសបញ្ជាក់ពាក់ព័ន្ធនឹង"អំពើអមនុស្សធម៌ផ្សេងៗទៀត"ថា "*ការយកចិត្តទុកដាក់ត្រូវតែមានធ្វើឡើង ដើម្បីកុំឲ្យមានការអនុវត្តហួសប្រមាណមួយ ដែលមានលក្ខណៈជ្រុលលើសពីអ្វីដែលមានចែងយ៉ាង ច្បាស់លាស់ ឬ ការបកស្រាយបទឧក្រិដ្ឋបែបមិនច្បាស់លាស់ និង ដែលមិនអាចរកការពិតឲ្យត្រឹមត្រូវ បាន។ ការបកស្រាយបែបមិនប្រាកដ នឹងធ្វើឲ្យប៉ះពាល់ដល់វិធានដែលកំណត់លក្ខខណ្ឌលើភាពជាក់ លាក់នៃការហាមឃាត់ផ្នែកព្រហ្មទណ្ឌ*"[92]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ រកឃើញបន្តទៀតថា ការ រៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងបរិបទនៃប្រទេសសេរ៉ាឡេអូន បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិ ក្នុងទម្រង់នៃ"អំពើអមនុស្សធម៌ផ្សេងៗទៀត" ដោយផ្អែកលើមូលដ្ឋាន (i) ជនរងគ្រោះ ទទួលរងរបួសផ្លូវកាយ ដោយសារត្រូវរងអំពើរំលោភសេពសន្ថវៈ និង អំពើហិង្សាផ្លូវភេទ ពលកម្ម

---

[89] *ដូចខាងលើ*។

[90] *ព្រះរាជអាជ្ញា ទល់នឹង* Stakić, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (IT-97-24-A), ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦, កថាខណ្ឌ ៣១៧។

[91] *សូមមើលឧទាហរណ៍៖ ព្រះរាជអាជ្ញា ទល់នឹង Milutinović*, សាលក្រម, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ (IT-05-87-T), ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩, កថាខណ្ឌ ១៧២។ *ព្រះរាជអាជ្ញា ទល់នឹង Krajišnik*, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ (IT-00-39-A), ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩, កថាខណ្ឌ ៣៣១។

[92] *ព្រះរាជអាជ្ញា ទល់នឹង Brima និងអ្នកផ្សេងទៀត*, សាលាដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការពិសេសសម្រាប់ ប្រទេសសេរ៉ាឡេអូន (SCSL-2004-16-A), ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨, កថាខណ្ឌ ១៨៥។

ដោយបង្ខំ ការធ្វើ ទារុណ្ណកម្មលើរូបរាងកាយ និង ការដកហូតសេរីភាព ដែលកើតឡើងច្រំដែល[93] និង (ii) លក្ខណៈនៃស្ថានទម្ងន់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មានភាពប្រហាក់ប្រហែលគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាក់លាក់ដទៃទៀត ដោយរាប់ទាំងការប្រព្រឹត្តិរបស់ចារី បរិយាកាសនៃអំពើហិង្សា ដែលក្នុងនោះជនរងគ្រោះត្រូវបានជាប់ពង្រត់ ភាពងាយរងគ្រោះរបស់ស្ត្រី និង ក្មេងស្រី និង ផលវិបាកនៃការប្រព្រឹត្តិរបស់ចារីលើរូបរាងកាយ ស្មារតី និង សុខភាពផ្លូវចិត្តរបស់ជនរងគ្រោះ[94] ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ក៏បានយល់ឃើញថា ចារីត្រូវតែបានដឹងថាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាបទឧក្រិដ្ឋ ដោយសារតែអំពោះនោះពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋអន្តរជាតិមួយ ឬច្រើន មានដូចជាការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការរំលោភសេពសន្ថវៈ ទាសករផ្លូវភេទ និង ការចាប់ពង្រត់[95]។

iv. <u>ការវាយតម្លៃលើ“អំពើអមនុស្សធម៌ផ្សេងៗទៀត”នៅ អ.វ.ត.ក</u>

57. អង្គបុរេជំនុំជម្រះ និង អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក សុទ្ធតែបានអនុវត្តស៊ីសង្វាក់គ្នានូវគោលការណ៍ដែលមានចែងនៅក្នុងរឿងក្តី *Kupreškić*។ អង្គបុរេជំនុំជម្រះគូសបញ្ជាក់ថា នៅពេលកំណត់ថាអ្វីការប្រព្រឹត្តិអ្វីមួយ ដែលឈានដល់កម្រិតនៃ “អំពើអមនុស្សធម៌ផ្សេងៗទៀត”បាន គេត្រូវយោងទៅលើការបំពារបំពានធ្ងន់ធ្ងរទៅលើច្បាប់អន្តរជាតិ ដែលគ្រប់គ្រងជម្លោះប្រដាប់អាវុធពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ រួមទាំងបញ្ញត្តិស្តីពីការរំលោភអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ឬ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើបទដ្ឋាននៃសិទ្ធិជាសារវ័ន្តរបស់មនុស្ស ដែលត្រូវបានការពារតាមច្បាប់អន្តរជាតិនៅពេលវេលាដែលពាក់ព័ន្ធ[96]។ ដើម្បីឈានដល់កម្រិតនៃស្ថានទម្ងន់ដែលជាលក្ខខណ្ឌកំណត់នោះ ការប្រព្រឹត្តិនោះតម្រូវឲ្យមានការដកហូតនូវសិទ្ធិមនុស្សជាមូលដ្ឋានដោយកម្រោល ឬ ដោយឥតលាក់លៀម[97]។

58. ការអនុវត្តគោលការណ៍ទាំងនេះ មានជាភ័ស្តុតាងជាពិសេសនៅក្នុងសំណុំរឿង ០០២។ ទោះបីជាសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា លក្ខខណ្ឌនៃការឃុំខ្លួនដែលអនុវត្តលើអ្នកជាប់

---

[93] *ដូចខាងលើ* កថាខណ្ឌ ១៩៩។

[94] *ដូចខាងលើ* កថាខណ្ឌ ២០០។

[95] *ដូចខាងលើ* កថាខណ្ឌ ២០១។

[96] សំណុំរឿងលេខ 002-D427/2/15, *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធារិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ១៦៤។

[97] សំណុំរឿងលេខ 001-E188, *សាលក្រម*, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ៣៧៨។

ឃុំនៅ ស-២១ បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដោយមិនបាច់យោងទៅបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ឬ យុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិ[98]យ៉ាងណាក៏ដោយ ក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះបានដកស្រង់យុត្តិសាស្ត្រតុលាការ ICTY ដើម្បីកំណត់ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស នៅក្នុងបរិបទនៃការឃុំខ្លួន ដែលឈានដល់កម្រិតនៃស្ថានទម្ងន់របស់បទឧក្រិដ្ឋផ្សេងៗទៀត ដែលមានកំណត់ក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក[99]។

59. ក្នុងករណីទាំងពីរនេះ អង្គជំនុំជម្រះមិនបានស្វះស្វែងកំណត់និយមន័យលើការប្រព្រឹត្តិ បើតាមការសន្មតគឺដោយសារតែការប្រព្រឹត្តិដែលពាក់ព័ន្ធនោះ (ឧទាហរណ៍ ដាក់ខ្នោះ ដាក់ច្រវ៉ាក់ ទារុណ្ណកម្មលើរាងកាយ ការផ្តល់អាហារមិនគ្រប់គ្រាន់) មានអំពើមួយ ឬ អំពើដែលងាយកំណត់បាន ដែលមិនតម្រូវឲ្យមាននិយមន័យ ក្នុងការអាចយល់ព្រំដែនរបស់វានោះទេ។

60. ផ្ទុយពីនេះ សម្រាប់បញ្ជាក់ធាតុផ្សំនៃការបាត់ខ្លួនដោយបង្ខំនៅក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូង បានពឹងផ្អែកលើនិយមន័យសម្រាប់ការប្រព្រឹត្តិដែលមានចែងក្នុងករណី *Justice Case*[100] និង សេចក្តីប្រកាសនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម និង អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY[101]។

61. ក្នុងការសន្និដ្ឋានថា ការបាត់ខ្លួនដោយបង្ខំមានលក្ខណៈ និង ស្ថានទម្ងន់ដូចគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាក់លាក់ផ្សេងៗទៀត[102] អង្គជំនុំជម្រះសាលាដំបូងបានពិចារណាសាលក្រមរបស់តុលាការ Nuremberg ដែលចាត់ទុកការបាត់ខ្លួនដោយបង្ខំថាជាឧក្រិដ្ឋកម្មសង្គ្រាម និង សាលក្រមក្រោយឆ្នាំ ១៩៧៥ និង លិខិតុបករណ៍ដែលបានទទួលស្គាល់ការប្រព្រឹត្តិបែបនេះ ថាមានស្ថានទម្ងន់

---

[98] សំណុំរឿងលេខ 001-E188, *សាលក្រម*, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ៣៧២-៣៧៣។

[99] សំណុំរឿងលេខ 002-E313, *សាលក្រម*, ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ៤៥៧។

[100] *សហរដ្ឋអាមេរិក ទល់នឹង Josef Alstotter និងអ្នកផ្សេងទៀត*, ការជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាម នៅចំពោះមុខសាលាក្តីយោធា Nuernberg ស្ថិតក្រោមច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ ១០, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៤៦-ខែ មេសា ឆ្នាំ ១៩៤៩, Vol. III។

[101] អង្គជំនុំជម្រះសាលាដំបូង បានកំណត់ធាតុផ្សំនៃការប្រព្រឹត្តិដូចតទៅ៖ "*ការបាត់ខ្លួនដោយបង្ខំកើតមានឡើងនៅពេលដែល (i) បុគ្គលម្នាក់អាចត្រូវបានដកហូតសេរីភាពរបស់ខ្លួន (ii) ការដកហូតសេរីភាពនេះត្រូវបានធ្វើឡើងតាមរយៈការបដិសេធមិនបង្ហាញព័ត៌មានទាក់ទងនឹងជោគវាសនា ឬ ទីកន្លែងដែលបុគ្គលពាក់ព័ន្ធនោះស្ថិតនៅ ឬ មិនទទួលស្គាល់ការដកហូតសេរីភាពនេះ ដោយបដិសេធចំពោះដំណោះស្រាយតាមផ្លូវច្បាប់ និង ការធានាផ្អែកនីតិវិធីចំពោះបុគ្គលនោះ និង (iii) ធាតុផ្សំទីមួយ និង ទីពីរត្រូវបានអនុវត្តដោយភ្នាក់ងាររដ្ឋ ឬ ដោយមានការអនុញ្ញាត ការគាំទ្រ ឬ ការយល់ព្រមពីរដ្ឋ ឬ អង្គការនយោបាយមួយ*" (សំណុំរឿងលេខ 002-E313, *សាលាក្រម*, ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ៤៤៨)។

[102] *ដូចខាងលើ*។

ធ្ងន់ធ្ងរបំផុត និង សេចក្តីសម្រេចក្រោយឆ្នាំ ១៩៧៥ របស់គណកម្មាធិការសិទ្ធិមនុស្សដែលបានរកឃើញថា ការបាត់ខ្លួនដោយបង្ខំបង្កើតបានជាការប្រព្រឹត្តិអមនុស្សធម៌ ឬ បន្ទាបបន្ថោក និង លិខិតុបករណ៍អន្តរជាតិថ្មីៗដែលបានបញ្ជាក់ថាការបាត់ខ្លួនដោយបង្ខំគឺជាអំពើដែលមានស្ថានទម្ងន់ធ្ងន់ធ្ងរបំផុត និង យុត្តិសាស្ត្រពីសាលាក្តីពិសេសដែលបានទទួលស្គាល់ថា ការបាត់ខ្លួនដោយបង្ខំអាចមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ក្នុងការបង្កើតបានជាអំពើអមនុស្សធម៌ផ្សេងៗទៀត និង ការចែងនៅលក្ខន្តិកៈទីក្រុងរ៉ូមអំពីការបាត់ខ្លួនដោយបង្ខំ ថាជាបទល្មើសដាច់ដោយឡែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាក់លាក់មួយ[103]។

62. អង្គជំនុំជម្រះសាលាដំបូង ក៏បានរកឃើញដែរថា ការជម្លៀសដោយបង្ខំបង្កើតបានជា"អំពើអមនុស្សធម៌ផ្សេង"មួយ ដោយកំណត់និយមន័យនៃបទល្មើសនោះ ដោយផ្អែកលើសាលក្រមរបស់តុលាការ Nuremberg និង ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង និង សាលដីការបស់តុលាការ ICTY[104]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការជម្លៀសដោយបង្ខំជាការប្រព្រឹត្តិដែលមានលក្ខណៈ និង ស្ថានទម្ងន់ស្រដៀងគ្នាទៅនឹងអំពើជាក់លាក់ផ្សេងៗទៀត ដោយសារតែអំពើនោះត្រូវបានចែងជាច្បាប់ក្នុងធម្មនុញ្ញតូក្យូ ធម្មនុញ្ញតុលាការNuremberg និង ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[105]។

v. <u>ការពិចារណាលើលក្ខខណ្ឌតម្រូវនៃ"អំពើអមនុស្សធម៌ផ្សេងៗទៀត"</u>

63. ការវិភាគខាងលើបង្ហាញថា តុលាការអនុវត្តវិធីសាស្ត្របែបប្រយ័ត្នប្រយែង ក្នុងការវាយតម្លៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដើម្បីធ្វើយ៉ាងណាធានាកុំឱ្យរំលោភបំពានគោលការណ៍នីត្យានុកូលភាព។ វិធីសាស្ត្រនេះតែងតែពាក់ព័ន្ធនឹងការយោងយុត្តិសាស្ត្រអន្តរជាតិ និង លិខិតុបករណ៍ច្បាប់ និង សិទ្ធិមនុស្សអន្តរជាតិ ដើម្បីកំណត់និយមន័យ ឬ បញ្ជាក់ធាតុផ្សំនៃការប្រព្រឹត្តិ រួមមានធាតុផ្សំសត្យានុម័ត និង ដើម្បីកំណត់ថាតើការប្រព្រឹត្តិនោះ មានលក្ខណៈដូចគ្នាទៅនឹងស្ថានភាព និង ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាក់លាក់ផ្សេងៗទៀតដែរឬយ៉ាងណា។ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានបញ្ជាក់កាលពីពេលថ្មីៗនេះថា ការកំណត់បញ្ហាណាមួយតាមរយៈដំណើរការនៃ"*ការបកស្រាយ និង*

---

[103] *ដូចខាងលើ*, កថាខណ្ឌ ៤៤៤-៤៤៧។

[104] ការជម្លៀសដោយបង្ខំគឺ " *(i)* ចេតនា, *(ii)* ការផ្លាស់ទីលំនៅដោយបង្ខំរបស់បុគ្គលជាច្រើន *(iii)* ឱ្យចាកចេញពីតំបន់មួយដែលពួកគេរស់នៅដោយស្របច្បាប់ *(iv)* ដោយគ្មានយុត្តិកម្មសមស្រប តាមរយៈការព្រួយបារម្ភអំពីសន្តិសុខរបស់ជនស៊ីវិល ឬ ភាពចាំបាច់ណាមួយផ្នែកយោធា" (*ដូចខាងលើ*, កថាខណ្ឌ ៤៥០)។

[105] *ដូចខាងលើ*, កថាខណ្ឌ ៤៥៤។

*ការបញ្ជាក់ឲ្យច្បាស់លើធាតុផ្សំនៃបទឧក្រិដ្ឋជាក់លាក់ណាមួយ ឬ លើនិយមន័យដែលគិតថាជាធាតុផ្សំនៃបទឧក្រិដ្ឋនោះ"* គឺមិនបំពានគោលការណ៍នីត្យានុកូលភាពនោះទេ[106]។ ការយោងប្រភពទាំងនេះ ក៏ជួយបំពេញគោលបំណងនៃការកំណត់ ថាតើជនជាប់ចោទអាចប្រមើលមើលដឹង និង អាចដឹងថាមានច្បាប់ចែង អំពីការស៊ើបអង្កេត និង ចោទប្រកាន់ចំពោះការប្រព្រឹត្តិបែបនោះ និង ថាការប្រព្រឹត្តិនោះមានលក្ខណៈខុសពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាក់លាក់ផ្សេងៗទៀត។

64. ការវិភាគនោះ គាំទ្រដល់ការសន្និដ្ឋានដែលថា ត្រូវតែមានបទដ្ឋានដែលទទួលស្គាល់ជាទំនៀមទម្លាប់មួយ ដែលភ្ជាប់ទៅនឹងសិទ្ធិសមស្របរបស់មនុស្សជាតិ ដែលភាព"អមនុស្សធម៌"នៃអំពើនោះ នឹងត្រូវវិនិច្ឆ័យ[107]។

65. យើងអនុវត្តតាមវិធីសាស្ត្រ ដែលត្រូវបានយកមកអនុវត្តក្នុងសម្អាងច្បាប់ ដូចដែលបានដកស្រង់ខាងលើ សម្រាប់គោលបំណងក្នុងការវាយតម្លៃលើនីត្យានុកូលភាពនៃការមានផ្ទៃពោះដោយបង្ខំ ដែលជា"អំពើអមនុស្សធម៌"មួយ ដើម្បីបញ្ជាក់ថាតើមាននិយមន័យដែលត្រូវបានទទួលស្គាល់ទូទៅ និង បទដ្ឋានដែលត្រូវបានទទួលស្គាល់ជាទំនៀមទម្លាប់ ពាក់ព័ន្ធនឹងការមានផ្ទៃពោះដោយបង្ខំក្នុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ដែរឬយ៉ាងណា។

vi. <u>និយមន័យនៃការមានផ្ទៃពោះដោយបង្ខំ</u>

66. និយមន័យក្នុងលក្ខន្តិកៈទីក្រុងរ៉ូមនៃការមានផ្ទៃពោះដោយបង្ខំ ដូចដែលបានបញ្ជាក់ខាងលើ គឺជានិយមន័យដំបូងនៅក្នុងច្បាប់អន្តរជាតិ[108] ដែលបង្កើតធាតុផ្សំសំខាន់ៗពីរចំពោះការប្រព្រឹត្តិនោះ រួមមានការធ្វើឲ្យស្ត្រីណាម្នាក់មានផ្ទៃពោះ និង ការរក្សាឲ្យគាត់មានផ្ទៃពោះតទៅទៀត។

---

[106] ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានបញ្ជាក់ថា "*គោលការណ៍នីត្យានុកូលភាព មិនរាំងតុលាការ មិនថានៅកម្រិតជាតិ ឬ អន្តរជាតិ មិនឲ្យកំណត់បញ្ហាណាមួយ តាមរយៈដំណើរការនៃការបកស្រាយ និង ការបញ្ជាក់ឲ្យច្បាស់ លើធាតុផ្សំនៃបទឧក្រិដ្ឋជាក់លាក់ណាមួយ ឬ លើនិយមន័យដែលគិតថាជាធាតុផ្សំនៃបទឧក្រិដ្ឋនោះ*"។ (សំណុំរឿងលេខ 004-D257/1/8, *សេចក្តីពិចារណាលើសំណើ អោ អាន សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ*,ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦, មតិយោបល់ស្តីពីមូលភាពនៃសំណើសុំ ដោយចៅក្រម Bauk និង Beauvallet, កថាខណ្ឌ ១៣)។

[107] Terhi Jyrkkiö, "'អំពើអមនុស្សធម៌ផ្សេងៗទៀត' ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ", *Helsinki Law Review*, 1 (2011), ទំព័រទី ២០៤។

[108] *សូមមើលកថាខណ្ឌខាងលើ ៥៥។*

67. ការដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីពឹងផ្អែក ពឹងផ្អែកលើនិយមនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម គឺមានបញ្ហាច្រើនចំណុច។ ទីមួយ ទោះបីមាត្រា ៩ថ្មី នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាតិ ចែងថាយុត្តាធិការលើអង្គហេតុរបស់ អ.វ.ត.ក បញ្ចូលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលមានកំណត់ន័យក្នុងលក្ខន្តិកៈទីក្រុងរ៉ូមក៏ដោយ ក៏មិនមានន័យថា បទឧក្រិដ្ឋទាំងនេះអាចយកអនុវត្តបាន ដោយមិនយកចិត្តទុកដាក់ត្រឹមត្រូវចំពោះគោលការណ៍នីត្យានុកូលភាពនោះដែរ។ បទល្មើសដែលត្រូវបានចោទប្រកាន់នៅ អ.វ.ត.ក ត្រូវតែមានចែងក្នុងច្បាប់ជាតិ ឬ ច្បាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដើម្បីឱ្យស្របតាមគោលការណ៍នីត្យានុកូលភាព[109]។ គោលការណ៍នីត្យានុកូលភាពក៏តម្រូវផងដែរថា បទល្មើសត្រូវតែជនជាប់ចោទអាចប្រមើលគ្រប់គ្រាន់ និង ថាច្បាប់ដែលចែងអំពីការទទួលខុសត្រូវចំពោះការប្រព្រឹត្តិបទល្មើសទាំងនោះ ត្រូវតែជនជាប់ចោទអាចដឹងថាមាន នៅពេលវេលាដែលពាក់ព័ន្ធនោះ[110]។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនបានពិចារណាឱ្យដិតដល់ថាតើការអនុវត្តនិយមន័យនោះ នៅក្នុងបរិបទកម្ពុជាប្រជាធិបតេយ្យ ធ្វើឱ្យប៉ះពាល់ដល់គោលការណ៍នីត្យានុកូលភាពដែរឬយ៉ាងណា។

68. ទីពីរ លក្ខន្តិកៈទីក្រុងរ៉ូមខ្លួនឯង ទទួលស្គាល់ថា ខ្លួនមិនអះអាងថានិយមន័យនោះមានចែងជាច្បាប់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិបច្ចុប្បន្នផង[111] ចុះទម្រាំច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលចូលជាធរមានក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ និងថា ដូច្នេះមិនគប្បីអនុវត្តវាដោយមិនបានត្រួតពិនិត្យសមស្របនោះទេ។ យោងលើចំណុចនេះ វាមានភាពពាក់ព័ន្ធដែលថា និយមន័យនៃការមានផ្ទៃពោះដោយបង្ខំនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម កើតចេញពីការសម្របសម្រួលរវាងរដ្ឋ ដែលមានរដ្ឋខ្លះជំទាស់ទៅនឹង

---

[109] សំណុំរឿងលេខ 001-F28, *សាលដីកាបណ្តឹងឧទ្ធរណ៍*, ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ៩១។ អង្គបុរេជំនុំជម្រះបានបញ្ជាក់បន្ថែមក្នុងសំណុំរឿងលេខ 002-D427/2/15, *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធារិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៩៦។ *សូមមើលផងដែរ* Case File No. 004-D257/1/8, *សេចក្តីពិចារណាលើសំណើ អោ អាន សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ,* យោបល់ស្តីពីមូលភាពនៃពាក្យសុំរបស់ចៅក្រម Baik និង Beauvallet, ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦ កថាខណ្ឌ ១។

[110] សំណុំរឿងលេខ 001-F28, *សាលដីកាបណ្តឹងឧទ្ធរណ៍,* ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៣, កថាខណ្ឌ ៩៦។

[111] មាត្រា ១០ នៃលក្ខន្តិកៈក្រុងរ៉ូម ចែងថា ពាក់ព័ន្ធនឹងផ្នែក II ស្តីពីយុត្តាធិការ, ការអាចទទួលយកបាន និង ច្បាប់ជាធរមាន៖ "*គ្មានចំណុចណាមួយក្នុងផ្នែកនេះ ត្រូវយកមកបកស្រាយ ដើម្បីដាក់កំហិត ឬ ធ្វើឱ្យប៉ះពាល់ដោយមធ្យោបាយណាមួយក៏ដោយដល់វិធានដែលមានស្រាប់ ឬ វិធានដែលកំពុងអភិវឌ្ឍនៃច្បាប់អន្តរជាតិ សម្រាប់គោលបំណងអ្វីផ្សេងក្រៅពីលក្ខន្តិកៈនេះ*"។

ចំណុចដែលថា តើវាគួរចាត់ទុកជាបទឧក្រិដ្ឋកើតដែរឬទេ[112] និង ដែលធ្វើឱ្យបញ្ញត្តិនេះត្រូវបានចាត់ទុកថា *"ជាបញ្ញត្តិដ៏លំបាកព្រាងជាងគេ និង ចម្រូងចម្រាសបំផុតមួយ"*[113]។ មានការខ្វែងគំនិតគ្នារវាងរដ្ឋដែលហាមប្រាមការពន្លូតកូន ឬ ការត្រួតពិនិត្យតឹងរឹងលើស្ត្រីក្នុងការមានកូន (ហើយដូច្នេះ រដ្ឋទាំងនោះមិនចង់ប្រថុយប្រថាន នៅក្នុងគោលនយោបាយជាតិរបស់ខ្លួន ក្នុងការកំណត់វាទៅជាបទល្មើសព្រហ្មទណ្ឌ) និង រដ្ឋដែលមិនហាមប្រាមចំណុចនេះ[114]។ ដូច្នេះ និយមន័យដែលបានមកនោះ គឺបានមកពីការសម្របសម្រួលដែលបានចរចាគ្នារវាងរដ្ឋទាំងនោះ ដោយផ្អែកលើភាពខុសគ្នាខ្លាំងនៅសេសសល់ សូម្បីតែក្នុងពេលកំពុងចរចា ម្ល៉ោះហើយគេមិនអាចចាត់ទុកវាថាឆ្លុះបញ្ចាំងអំពីការយល់ជារួមមួយចំពោះនិយមន័យនៃពាក្យនេះនោះទេ សូម្បីតែនៅក្នុងច្បាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ក៏ដោយ។

69. ទីបី ទោះបីជាយកមកអនុវត្តនៅ អ.វ.ត.ក ធាតុផ្សំនៃនិយមន័យក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ពាក់ព័ន្ធនឹងការឃុំឃាំងដោយបង្ខំ និង ចេតនាផ្លាស់ប្តូរសមាភាពនៃជាតិពន្ធុរបស់ប្រជាជន នឹងមិនទំនងជាអាចបំពេញលក្ខខណ្ឌបាន ដោយកាលៈទេសៈពិត ដែលពាក់ព័ន្ធនឹងការមានផ្ទៃពោះដោយបង្ខំនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ និយមន័យនៃការមានផ្ទៃពោះដោយបង្ខំនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ត្រូវបានព្រាងដើម្បីជាការឆ្លើយតបទៅនឹងអំពើឃោរឃៅ ដែលត្រូវបានប្រព្រឹត្តលើស្ត្រីនៅប្រទេសបូស្នៀ និង រ៉្វាន់ដានៅដើមទសវត្សឆ្នាំ ១៩៩០ ដែលបានកើតឡើងក្នុងបរិបទនៃការផ្លាស់ប្តូរសមាភាពនៃជាតិពន្ធុនៃ

---

[112] *សូមមើល* Alyson M. Drake, "មានគោលបំណងការពារក្រុមជាតិពន្ធុ ឬ ស្ត្រី? ការសម្លឹងមើលលើការមានផ្ទៃពោះដោយបង្ខំ នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម", *William & Mary Journal of Women and the Law*, 18(3), 2012, ទំព័រទី ៦០៦។

[113] Christopher Hall, Joseph Powderly និង Niamh Hayes, "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ", in Triffterer & Ambos (Eds.), *លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ៖ បទអត្ថាធិប្បាយ*, 3rd edition 2016, Munich, ទំព័រទី ២៧៥។

[114] ជាពិសេស, អញ្ញត្រកម្មត្រូវបានលើកឡើងដោយ the Holy See និង Arab States។ The Holy See សម្តែងក្តីព្រួយបារម្ភថា ការដាក់ការមានផ្ទៃពោះដោយបង្ខំឱ្យក្លាយជាបទល្មើសព្រហ្មទណ្ឌ អាចត្រួសត្រាយផ្លូវដើម្បីឈានទៅអនុញ្ញាតឱ្យរម្លូតកូនដោយស្របច្បាប់ រួមទាំងការមានកូនដោយសារការរំលោភសេពសន្ថវៈ។ The Arab States បញ្ជាក់អំពីក្តីបារម្ភថា បញ្ញត្តិនេះអាចដាក់សម្ពាធដល់ពួកគេ ក្នុងការអនុម័តច្បាប់ក្នុងការអនុញ្ញាតឱ្យរម្លូតកូនដោយស្របច្បាប់ និង ក្តីកង្វល់ថា បញ្ញត្តិទាំងនោះនឹងជ្រៀតជ្រែកដល់ទំនាក់ទំនងប្តីប្រពន្ធ រួមទាំងការរំលោភសេពសន្ថវៈនៅក្នុងចំណងអាពាហ៍ពិពាហ៍ ដែលមិនត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋនៅរដ្ឋជាក់លាក់មួយចំនួន (Kristen Boon, "ការរំលោភសេពសន្ថវៈ និង ការមានផ្ទៃពោះដោយបង្ខំនៅក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ៖ សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ, ស្វ័យភាព និង ការយល់ព្រម", *ការពិនិត្យច្បាប់សិទ្ធិមនុស្សរបស់ប្រទេសកូឡុំប៊ី*, ៣២, ២០០០-២០០១, ទំព័រទី ៦៣៩-៦៤០។ Soh Sie Eng Jessie, "ការមានផ្ទៃពោះដោយបង្ខំ៖ ការចែងជាច្បាប់នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម និង ទស្សនៈវិស័យអំពីអំពើប្រល័យពូជសាសន៍របស់វា", *ទស្សនាវដ្តីប្រទេសណូវ៉ែលហ្សេឡង់ស្តីពីច្បាប់សាធារណៈអន្តរជាតិ*, ៤, ២០០៦, ទំព័រទី ៣២៣-៣២៥។ Rhonda Copelon, "ឧក្រិដ្ឋកម្មយេនឌ័រជាឧក្រិដ្ឋកម្មសង្គ្រាម៖ Integrating Crimes against Women into International Criminal Law", *McGill Law Journal*, 46, 2000-2001, p. 236).

01330306



ទឹកដីមួយ និង ក្នុងបរិបទនៃការបំភិតបំភ័យ ឬ បន្ទាបបន្ថោកតម្លៃរបស់ប្រជាជននៅមូលដ្ឋាន[115]។ ចំណុចនេះមានលក្ខណៈប្លែកគ្នាពីបរិបទប្រទេសកម្ពុជា ដែលក្នុងនោះមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចោទប្រកាន់ថា មានគោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមួយ ត្រូវបានអនុវត្តដើម្បីបង្កើនចំនួនប្រជាជន[116]។ លទ្ធផលនៃគោលនយោបាយនោះគឺការបង្កាត់ពូជមនុស្ស។ ប៉ុន្តែដើម្បីបំពេញគោលបំណងក្នុងការបង្ហាញឱ្យឃើញ ថាតើពិតជាមាននិយមន័យនៃការមានផ្ទៃពោះដោយបង្ខំ និង ថាតើវាអាចមានភាពពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ ១៩៧៦ ដល់ ឆ្នាំ ១៩៧៩ ដែរឬយ៉ាងណា ត្រូវតែបង្ហាញឱ្យឃើញ ថាតើការប្រព្រឹត្តិនោះតម្រូវឱ្យមាន ឧទាហរណ៍ការបង្កឱ្យមានផ្ទៃពោះដោយបង្ខំ ការមិនអនុញ្ញាតឱ្យប្រើវិធីពន្យារកំណើត ការទប់ស្កាត់មិនឱ្យស្ត្រីបញ្ចប់ការមានផ្ទៃពោះ ឬ ការឃុំឃាំងស្ត្រីមានផ្ទៃពោះដោយបង្ខំ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏មិនបានបង្ហាញអំពីថាតើទំហំនៃស្ថានភាពដែលស្ត្រីមានផ្ទៃពោះប្រឈម នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលកើតឡើងដោយសារលក្ខខណ្ឌនៃស្ថានភាពរស់នៅ ដែលប្រជាជនស៊ីវិលទូទៅប្រឈម។

70. លិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិនៅមុនឆ្នាំ ១៩៧៥ គ្មានចែងអំពីនិយមន័យនៃការមានផ្ទៃពោះដោយបង្ខំនេះទេ និងគ្មានចែងអំពីបទដ្ឋានសិទ្ធិមនុស្សច្បាស់លាស់មួយ ដើម្បីឱ្យយើងអាចវាយតម្លៃការមានផ្ទៃពោះដោយបង្ខំនេះបាននោះទេ។ លិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិជាច្រើន ទទួលស្គាល់សិទ្ធិនៃសុចរិតភាពផ្លូវកាយ និង សេរីភាពក្នុងការរួចផុតពីការបំពានសិទ្ធិនៃជីភាពឯកជន និង គ្រួសាររបស់នរណាម្នាក់[117] ដែលមានបញ្ចូល"*សិទ្ធិស្វ័យភាពបុគ្គល សិទ្ធិអភិវឌ្ឍបុគ្គល និង សិទ្ធិបង្កើត និង អភិវឌ្ឍសម្ព័ន្ធភាពជាមួយមនុស្សឯទៀត និង ពិភពខាងក្រៅ*"[118]។

---

[115] Alyson M. Drake, "មានគោលបំណងការពារក្រុមជាតិពន្ធុ ឬ ស្ត្រី? ការសម្លឹងមើលលើការមានផ្ទៃពោះដោយបង្ខំ នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម", *William & Mary Journal of Women and the Law*, 18(3), 2012, ទំព័រទី ៦០២។ Christopher Hall, Joseph Powderly និង Niamh Hayes, "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ", in Triffterer & Ambos (Eds.), *លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ៖ បទអត្ថាធិប្បាយ*, 3rd edition 2016, Munich, ទំព័រទី ២៧៥។

[116] សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ ១៧។

[117] មាត្រា ១៦ នៃសេចក្តីថ្លែងការណ៍ជាសាកលឆ្នាំ ១៩៤៨ ស្តីពីសិទ្ធិមនុស្ស ("UDHR") ចែងថា បុរស និង ស្ត្រីដែលពេញវ័យមានសិទ្ធិរៀបការ និង រៀបគ្រួសារ។ មាត្រា ៨ នៃអនុសញ្ញាអឺរ៉ុបឆ្នាំ ១៩៥០ សម្រាប់ការពារសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន ("ECHR") ចែងថា សិទ្ធិទទួលបានការគោរពជីវិតឯកជន និង គ្រួសារ។ មាត្រា ១៧ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ("ICCPR") ចែងថា គ្មានជនណាម្នាក់ត្រូវរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬ ដោយខុសច្បាប់ ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន សំបុត្រឆ្លងឆ្លើយរបស់ខ្លួន ឬ ត្រូវរងការប៉ះពាល់ដោយខុសច្បាប់ទៅលើកិត្តិយស និង កេរ្តិ៍ឈ្មោះរបស់ខ្លួន

71. សិទ្ធិមានជម្រើសក្នុងការបន្តពូជ ត្រូវបានទទួលស្គាល់ច្បាស់លាស់ជាលើកដំបូង ក្នុងសេចក្តីប្រកាសរបស់ក្រុងតេហ៊ានឆ្នាំ ១៩៦៨ នៅក្នុងសន្និសីទអន្តរជាតិក្រុងតេហ៊ានស្តីពីសិទ្ធិមនុស្ស ដែលបានចែងថា ឱពុកម្តាយមានសិទ្ធិជាមូលដ្ឋានមួយ ក្នុងការសម្រេចដោយសេរី និង ដោយមានការទទួលខុសត្រូវលើចំនួនកូន និង ភាពរង្វើលនៃការមានកូន[119]។ ចំណុចនេះត្រូវបានចែងបញ្ជាក់នៅក្នុងសន្និបាតឆ្នាំ ១៩៧៩ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី[120]។

72. ទំនាក់ទំនងគ្នារវាងជម្រើសក្នុងការបន្តពូជ និង អំពើហិង្សាផ្លូវភេទ នៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ មិនត្រូវបានចែងច្បាស់លាស់នៅឡើយទេ រហូតដល់ឆ្នាំ ១៩៩៣ ទើបមានចែងច្បាស់លាស់ក្នុងសេចក្តីប្រកាស និង កម្មវិធីសកម្មភាពទីក្រុងវីយែន[121] និង សេចក្តីប្រកាស និង ទម្រង់សកម្មភាពទីក្រុងប៉េកាំងឆ្នាំ ១៩៩៥[122]។ ក្នុងឆ្នាំ ១៩៩៨ គណកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានអនុម័ត

---

ឡើយ។ បន្ថែមលើសិទ្ធិទាំងនេះ លិខិតុបករណ៍ផ្សេងៗទៀតបានចែងអំពីការការពារជីវិត សេរីភាព និង សន្តិសុខរបស់បុគ្គល (មាត្រា ៣ នៃ UDHR ឆ្នាំ ១៩៤៨, មាត្រា ៥ នៃ ECHR ឆ្នាំ ១៩៥០), ការការពារស្ត្រីពីការវាយប្រហារលើកិត្តិយសរបស់ពួកគាត់ ក្នុងពេលមានជម្លោះប្រដាប់អាវុធ (មាត្រា ២៧(២) នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV ឆ្នាំ ១៩៤៩ និង មាត្រា ៧៦ នៃពិធីសារបន្ថែម I ឆ្នាំ ១៩៧៧), និង ការហាមឃាត់ចំពោះអំពើទារុណ្ឌកម្ម ការប្រព្រឹត្តិឃោរឃៅ អមនុស្សធម៌ ឬ បន្ទាបបន្ថោក ឬ ការដាក់ទណ្ឌកម្ម (មាត្រា ៥ នៃ UDHR ឆ្នាំ ១៩៤៨, មាត្រា ៧ នៃ ICCPR ឆ្នាំ ១៩៦៦)។

118 ECtHR, *Tysiqc ទល់នឹង ប្រទេសប៉ូឡូញ*, ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧, កថាខណ្ឌ ១០៧។

119 មាត្រា ១៦ នៃសេចក្តីប្រកាសទីក្រុងតេហ៊ានចែងថា៖ "*ឪពុកម្តាយមានសិទ្ធិជាមូលដ្ឋាន ក្នុងការសម្រេចដោយសេរី និង ប្រកបដោយការទទួលខុសត្រូវ ចំពោះចំនួនកូន និង ចំនួនរង្វើលនៃការមានកូនរបស់ពួកគាត់*" (ច្បាប់ចុងក្រោយនៅក្នុងសន្និសីទអន្តរជាតិស្តីពីសិទ្ធិមនុស្ស, ទីក្រុងតេហ៊ាន, ចុះថ្ងៃទី ២២ ខែ មេសា ដល់ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៦៨, U.N. Doc. A/Conf. 32/41 at 3)។

120 មាត្រា ១៦(១)(ង) នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រី ចែងថា ស្ត្រីមានសិទ្ធិស្មើគ្នានឹងបុរស "*ក្នុងការសម្រេចដោយសេរី និង ប្រកបដោយការទទួលខុសត្រូវ លើចំនួនកូន និង ភាពរង្វើលនៃការមានកូនរបស់ខ្លួន...*"។

121 សេចក្តីប្រកាសទីក្រុងវីយែនចែងថា៖ "*ការរំលោភបំពានសិទ្ធិមនុស្សរបស់ស្ត្រី នៅក្នុងស្ថានភាពនៃជម្លោះប្រដាប់អាវុធ ជាការបំពារបំពានគោលការណ៍ជាសារវ័ន្តនៃច្បាប់សិទ្ធិមនុស្ស និង មនុស្សធម៌អន្តរជាតិ។ ការរំលោភបំពានទាំងនេះ រួមមានការធ្វើមនុស្សឃាត ការរំលោភសេពសន្ថវៈជាលក្ខណៈប្រព័ន្ធ ទេសករផ្លូវភេទ និង ការមានផ្ទៃពោះដោយបង្ខំ សុទ្ធតែតម្រូវឲ្យមានការឆ្លើយតបប្រកបដោយប្រសិទ្ធិភាព*"។ (សេចក្តីប្រកាសទីក្រុងវីយែន និង កម្មវិធីសកម្មភាព, សន្និសីទពិភពលោកស្តីពីសិទ្ធិមនុស្ស, pt. 2, កថាខណ្ឌ ៣៨ (1993))។

122 សេចក្តីប្រកាសក្រុងប៉េកាំងចែងថា៖ "*ជារឿយៗ ភាគីនៃជម្លោះចាប់រំលោភសេពសន្ថវៈលើស្ត្រីដោយគ្មានការដាក់ទោស ដោយជួនកាលប្រើប្រាស់ការរំលោភសេពសន្ថវៈជាលក្ខណៈប្រព័ន្ធ ធ្វើជាយុទ្ធសាស្ត្រសង្គ្រាម និង ភេរវកម្ម។ ស្ត្រី និង ក្មេងស្រីជាជនរងគ្រោះនៃការធ្វើមនុស្សឃាត,អំពើភេរវកម្ម,ការធ្វើទារុណ្ឌកម្ម, ការបាត់ខ្លួនដោយបង្ខំ, ទាសករផ្លូវភេទ, ការរំលោភសេពសន្ថវៈ, ការបំពារបំពានផ្លូវភេទ និង ការមានផ្ទៃពោះដោយបង្ខំ នៅក្នុងស្ថានភាពនៃជម្លោះប្រដាប់អាវុធ ជាពិសេសកើតចេញពី*

សេចក្តីសម្រេចមួយថ្កោលទោសការរំលោភសិទ្ធិស្ត្រីនៅក្នុងជម្លោះប្រដាប់អាវុធ ដោយរួមបញ្ចូលការមានផ្ទៃពោះដោយបង្ខំផង[123]។

73. ដោយសារនៅឆ្នាំ ១៩៧៥ នៅក្នុងប្រទេសកម្ពុជា គ្មានច្បាប់ប្រឆាំងការមានផ្ទៃពោះដោយបង្ខំ និង ការរម្លូតកូនត្រូវបានចែងច្បាស់ថាជាបទឧក្រិដ្ឋ[124] និងថា សូម្បីសព្វថ្ងៃ គ្មានការឯកភាពរួមជាសាកលណាមួយ លើសិទ្ធិរម្លូតកូនសូម្បីតែនៅក្រោយការរំលោភសេពសន្ថវៈ[125] គេមិនទាន់អាចនិយាយបានថា សិទ្ធិស្តីពីសុចរិតភាពនៃរាងកាយ សេរីភាពរួចផុតពីការជ្រៀតជ្រែកក្នុងជីវភាពគ្រួសារ និង ជីវភាពឯកជន និង សិទ្ធិក្នុងការសម្រេចចំនួនកូន និង ភាពរង្វើលនៃការមានកូន ត្រូវបានគេទទួលស្គាល់ទូលំទូលាយថាជាសិទ្ធិជាមូលដ្ឋាននៅឡើយទេ ទោះការបំពារបំពានធ្ងន់ធ្ងរលើសិទ្ធិទាំងនេះ អាចបង្កើតបាន"អំពើអមនុស្សធម៌ផ្សេងៗទៀត"។ ការខ្វះយុត្តិសាស្ត្រក្នុងការវាយតម្លៃលើលក្ខណៈនៃការបំពារបំពាននេះហើយ ដែលកាន់តែធ្វើឲ្យមានភាពមិនច្បាស់លាស់ និង ទុកបញ្ហាពាក់ព័ន្ធនឹងធាតុផ្សំតម្រូវនៃការប្រព្រឹត្តិនៅក្នុងបរិបទរបបកម្ពុជាប្រជាធិតេយ្យ ឲ្យតែគ្មានដំណោះស្រាយនៅឡើយ។

74. ការទទួលស្គាល់ដែលមានលក្ខណៈសន្សឹមៗ និង យឺតនៃការមានផ្ទៃពោះដោយបង្ខំថាជាបទឧក្រិដ្ឋក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិបែបនេះ បង្ហាញឲ្យឃើញភាពខ្វែងគំនិតគ្នារវាង់អ្នកប្រកាន់ទ្រឹស្តីសមូហភាពនិយម និង ទំនៀមទម្លាប់ច្បាប់ដែលប្រកាន់បុគ្គលនិយម ដែលក្នុង នោះទម្លាប់ខុសប្លែកគ្នា បង្កើតបានជាទស្សនៈខ្វែងគ្នាស្តីពីជម្រើសក្នុងការបន្តពូជ ទំនាក់ទំនងផ្លូវភេទ ការរម្លូតកូន និង ការពង្រីកវិសាលភាពនៃសិទ្ធិស្ត្រី[126]។ ទោះបីជាគំនិតនៃស្វ័យភាពបុគ្គល និង ការបន្តពូជមានប្រៀបយ៉ាងណាក៏ដោយ

---

*គោលនយោបាយនៃការបោសសម្អាតជាតិពន្ធុ និង ទម្រង់នៃអំពើហិង្សាដែលលេចឡើងថ្មីៗដទៃទៀត*" (សេចក្តីប្រកាសទីក្រុងប៉េកាំង និង ទម្រង់សម្រាប់សកម្មភាព, សន្និសីទពិភពលោកលើកទីបួនស្តីពីស្ត្រី ៨៤, កថាខណ្ឌ ១៣៥ (1996))។

[123] គណៈកម្មាធិការសិទ្ធិមនុស្ស, សេចក្តីសម្រេច 1998/52, ការលុបបំបាត់អំពើហិង្សាប្រឆាំងស្ត្រី, ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៩៨, មាត្រា ៤។

[124] មាត្រា ៤៥៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ បានដាក់ការរម្លូតកូនជាបទល្មើសព្រហ្មទណ្ឌ។

[125] នៅឆ្នាំ ២០១១, មានរដ្ឋតែ ៥៨ ប៉ុណ្ណោះក្នុងចំណោមរដ្ឋ ១៩៦ អនុញ្ញាតឲ្យមានការរម្លូតកូនដោយគ្មានការរឹតត្បិត និង មានតែរដ្ឋ ៩៩ ប៉ុណ្ណោះដែលអនុញ្ញាតឲ្យមានការរម្លូតកូន ក្នុងករណីមានការរំលោភសេពសន្ថវៈ ឬ ស្មន្ធការ (មជ្ឈមណ្ឌលស្រាវជ្រាវ Pew, "គោលនយោបាយរម្លូតកូនពិភពលោក", អាចរកបាននៅថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៦ តាមរយៈ http://www.pewresearch.org/interactives/global-abortion/, ដោយបានដកស្រង់នាយកដ្ឋានសេដ្ឋកិច្ច និង សង្គមកិច្ចរបស់អង្គការសហប្រជាជាតិ, "គោលនយោបាយរម្លូតកូនពិភពលោកឆ្នាំ ២០១៣")។

[126] *សូមមើល* Kristen Boon, "ការរំលោភសេពសន្ថវៈ និង ការមានផ្ទៃពោះដោយបង្ខំនៅក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ៖ សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ស្វ័យភាព និង ការយល់ព្រម", *ការពិនិត្យច្បាប់សិទ្ធិមនុស្សរបស់ប្រទេសកូឡុំប៊ី*, ៣២, ២០០០-២០០១, ទំព័រទី ៦៤៣។

គ្មានភស្តុតាងគ្រប់គ្រាន់អំពីការអនុវត្តរបស់រដ្ឋ ឬ *opinio juris* ដើម្បីអះអាងថា ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ការរំលោភបំពានលើស្វ័យភាពទាំងនោះ ត្រូវបានចាត់ដោយសហគមន៍អន្តរជាតិ ថាជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិជាមូលដ្ឋានរបស់មនុស្សនោះទេ។

75. អំពើជាច្រើន ត្រូវបានរកឃើញពីពេលមុន ថាបង្កើតបានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" រួមមានការចាក់ ឬ កាត់សាច់ ការវាយដំ និង ទម្រង់ផ្សេងៗទៀតនៃព្យសនកម្មធ្ងន់ធ្ងរលើរាងកាយ ការធ្វើឱ្យរបួសរាងកាយ និង ផ្លូវចិត្ត ការជម្លៀសដោយបង្ខំ ការប្រព្រឹត្តិបែបអមនុស្សធម៌ និង បន្ទាបបន្ថោក ការបាត់ខ្លួនដោយបង្ខំ ការធ្វើទារុណកម្ម អំពើហិង្សាផ្លូវភេទ និង ការដាក់ឃុំឃាំងក្នុងស្ថានភាពអមនុស្សធម៌[127]។ អំពោះទាំងនេះជាអំពើដាច់ដោយឡែកមួយៗ និង ខុសគ្នា ដែលមិនចាំបាច់មាននិយមន័យ ដើម្បីអាចយល់ធាតុផ្សំរបស់វា ឬ ប្រសិនបើមានអំពើច្រើនរួមគ្នា សុទ្ធតែត្រូវបានកំណត់និយមន័យរួចហើយ នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ឬ មានបញ្ចូលនៅក្នុងសិទ្ធិមនុស្សអន្តរជាតិដែលមានការទទួលស្គាល់ទូលំទូលាយមួយ មុនការវាយតម្លៃវាថាជា"អំពើអមនុស្សធម៌ផ្សេងទៀត"។

76. ការមានផ្ទៃពោះដោយបង្ខំ មានធាតុផ្សំជាច្រើន និង ដោយសារខ្វះនិយមន័យដែលមានការទទួលស្គាល់ជាទូទៅមួយចំពោះការប្រព្រឹត្តិនេះនៅឆ្នាំ ១៩៧៥ គោលគំនិតថាតើអ្វីខ្លះជាធាតុផ្សំ ទាំងនោះ នៅមានលក្ខណៈស្រពិចស្រពិលខ្លាំង ដែលមិនអាចចាត់ទុកវាថាជាបទដ្ឋានសិទ្ធិមនុស្សជាទំនៀមទម្លាប់ដែលត្រូវបានទទួលស្គាល់ ដែលការបំពារបំពានធ្ងន់ធ្ងរលើវានឹងឈានដល់កម្រិតនៃ"អំពើអមនុស្សធម៌ផ្សេងៗទៀត"បាននោះទេ។ ដូច្នេះ ធាតុផ្សំនៃការប្រព្រឹត្តិនោះ មានលក្ខណៈមិនច្បាស់លាស់ ដែលនាំឲ្យជនត្រូវចោទមិនអាចប្រមើលមើលដឹង និង មិនដឹងថាមានចែងក្នុងច្បាប់ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ដែលថាគេអាចស៊ើបអង្កេត និង ចោទប្រកាន់លើការប្រព្រឹត្តិបែបនេះ។ មិនតែប៉ុណ្ណោះ ពាក់ព័ន្ធនឹងគោលការណ៍សន្មតបែបតឹងរឹង ភាពមន្ទិលចំពោះនិយមន័យនៃការមានផ្ទៃពោះដោយបង្ខំ ត្រូវបានជាប្រយោជន៍ជនត្រូវចោទ។

77. ដូច្នេះ គ្មានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីនិយាយថា ការអនុវត្តក្របខណ្ឌសម្រាប់វិភាគ"អំពើអមនុស្សធម៌ផ្សេងៗទៀត"នៃការមានផ្ទៃពោះដោយបង្ខំ បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃ

---

[127] ដូចសង្ខេបនៅក្នុងករណី *ព្រះរាជអាជ្ញា ទល់នឹង Prlić និងអ្នកផ្សេងៗទៀត*, សាលក្រម, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-04-74-T), ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣, វ៉ុល ១, កថាខណ្ឌ ៧៩, និង *ព្រះរាជអាជ្ញា ទល់នឹង Brima និងអ្នកផ្សេងៗទៀត*, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (SCSL-2004-16-A), ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨, កថាខណ្ឌ ១៨៤។

"អំពើអមនុស្សធម៌ផ្សេងទៀត" ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បាននោះទេ។ គោលារណ៍នីត្យានុកូលភាព នឹងត្រូវរងការរំលោភបំពាន ប្រសិនបើជនត្រូវចោទត្រូវរកការស៊ើបអង្កេត និង ចោទប្រកាន់ចំពោះការប្រព្រឹត្តិដូច្នេះនោះ។

**ក) នីត្យានុកូលភាពនៃការបង្កឱ្យមានផ្ទៃពោះដោយបង្ខំ ជា"អំពើអមនុស្សធម៌ផ្សេង"មួយពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩**

78. សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលស្នើសុំស៊ើបអង្កេតលើ *ការបង្កឱ្យមានផ្ទៃពោះដោយបង្ខំ* ដែលមានលក្ខណៈទូទៅដូច្នេះ គឺកាន់តែមានបញ្ហា។ ដំបូង និយមន័យនៃការបង្កឱ្យមានផ្ទៃពោះដោយបង្ខំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលពាក់ព័ន្ធនឹងការបង្កឱ្យស្ត្រី ឬ ក្មេងស្រីមានផ្ទៃពោះដោយបង្ខំដែលផ្ទុយពីឆន្ទៈពួកគាត់នោះ[128] មិនបានកំណត់ដោយពន្យល់ព័ត៌មានលម្អិតអំពីធាតុផ្សំដែលតម្រូវនៃការប្រព្រឹត្តិនោះ រួមទាំងធាតុផ្សំសត្យានុម័តដែលចាំបាច់ផង។ កាលណាការប្រព្រឹត្តិពាក់ព័ន្ធនឹងអំពើជាក់លាក់ច្រើន ធាតុផ្សំត្រូវបង្ហាញឱ្យបានច្បាស់លាស់ និង អាចយល់បាននៅឆ្នាំ ១៩៧៥ ដើម្បីកំណត់ថាតើវាជាការប្រព្រឹត្តិដែលឈានដល់កម្រិតនៃ"អំពើអមនុស្សធម៌ផ្សេងទៀត"ដែរឬយ៉ាងណា។ ចំពោះចំណុចនេះ ការវិភាគខាងលើពាក់ព័ន្ធនឹងការខ្វះនិយមន័យនៃការមានផ្ទៃពោះដោយបង្ខំនៅឆ្នាំ ១៩៧៥[129] អនុវត្តបានដូចគ្នាចំពោះការបង្កឱ្យមានផ្ទៃពោះដោយបង្ខំ។

79. ជាការសំខាន់ ត្រូវកំណត់ធាតុផ្សំនៃការប្រព្រឹត្តិ រួមទាំងធាតុផ្សំសត្យានុម័តជាក់លាក់ សម្រាប់កំណត់ថាតើបទចោទត្រួតគ្នាមួយ អាចធ្វើឡើងពាក់ព័ន្ធនឹងការមានផ្ទៃពោះដោយបង្ខំ បន្ថែមលើបទឧក្រិដ្ឋដទៃទៀតនៅក្នុងយុត្តាធិការ អ.វ.ត.ក។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា អាចដាក់ពិរុទ្ធភាពត្រួតគ្នាបាន ចំពោះបទល្មើសដែលពាក់ព័ន្ធនឹងការព្រឹត្តិពិតដូចគ្នាតែមួយ ប៉ុន្តែធ្វើបានតែក្នុងករណីដែលបទល្មើសទាំងនោះ"*មានលក្ខណៈដាច់ដោយឡែកពីគ្នាយ៉ាងគ្រប់គ្រាន់ ឬ មាន"ធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័ត" ដែលគ្មានកំណត់នៅក្នុងបទល្មើសដទៃទៀត*"[130]។ សហព្រះរាជអាជ្ញាអន្តរជាតិ

---

[128] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ៣, ១១។

[129] *សូមមើលដូចខាងលើ* កថាខណ្ឌ ៧០-៧៤។

[130] សំណុំរឿងលេខ 001-F28, សាលដីកាបណ្តឹងឧទ្ធរណ៍, ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ២៨៨, ដកស្រង់ *ព្រះរាជអាជ្ញា ទល់នឹង Delalić និងអ្នកផ្សេងៗទៀត*, សាលាដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (IT-96-21-A), ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១, កថាខណ្ឌ ៤១២-៤១៣។

គួសបញ្ជាក់អំពីព្យសនកម្ម ដែលបណ្តាលមកពីការបង្កឲ្យមានផ្ទៃពោះដោយបង្ខំ[131] ប៉ុន្តែ ព្យសនកម្មនោះអាចមិនខុសគ្នាពីព្យសនកម្មដែលបណ្តាលមកពីការមានផ្ទៃពោះដោយសារការរំលោភសេពសន្ថវៈ ឬ ការរួមភេទក្នុងចំណងអាពាហ៍ពិពាហ៍ដោយបង្ខំ។ អវត្តមានធាតុផ្សំសត្យានុម័តជាក់លាក់ ការរំលោភសេពសន្ថវៈ និង ការបង្កឲ្យមានផ្ទៃពោះដោយបង្ខំ ក្នុងទម្រង់នៃ"អំពើអមនុស្សធម៌ផ្សេងទៀត" មិនអាចកំណត់និយមន័យឲ្យបានច្បាស់ដល់កម្រិតដែលតម្រូវ ដើម្បីអាចផ្តល់សច្ចភាពផ្លូវច្បាប់ដល់ជនត្រូវចោទ។

80. ទីពីរ គោលការណ៍នីត្យានុកូលភាព តម្រូវឲ្យមានការវិភាគតឹងរឹងមួយដើម្បីបញ្ជាក់ថា មានសិទ្ធិជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាទូទៅក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែលអាចរងការរំលោភបំពានធ្ងន់ធ្ងរដោយការបង្កឲ្យមានផ្ទៃពោះដោយបង្ខំ។ លក្ខណៈនៃសិទ្ធិដូចដែលសហព្រះរាជអាជ្ញាបានកំណត់ថាជាសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ស្វ័យភាព និង ជម្រើសបន្តពូជ[132]នោះ និងស្ថានទម្ងន់នៃការបំពារបំពានសិទ្ធិនោះ នៅមិនទាន់បានកើតឡើងនៅឡើយក្នុងទសវត្សឆ្នាំ ១៩៧០។ ចំណុចមានបញ្ជាក់ភ័ស្តុតាងដោយការពិត ដែលថាសិទ្ធិឪពុកម្តាយក្នុងការសម្រេចដោយសេរី និង ប្រកបដោយការទទួលខុសត្រូវនូវចំនួនកូន និង ភាពរង្វើលនៃការមានកូន ត្រូវបានទទួលស្គាល់ជាដំបូងនៅក្នុងឆ្នាំ ១៩៦៨ និង ត្រូវថ្កោលទោសតែក្នុងបរិបទនៃជម្លោះប្រដាប់អាវុធក្នុងឆ្នាំ ១៩៩៣[133] ដោយគ្មានសម្អាងហេតុនៅក្នុងយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិ ឬ យុត្តិសាស្ត្រសិទ្ធិមនុស្សអន្តរជាតិ ស្តីពីការបំពារបំពានសិទ្ធិទាំងនោះ នៅពេលនោះ។ លក្ខណៈនៃសិទ្ធិទាំងនេះនៅឆ្នាំ ១៩៧៥ មើលទៅរឹតតែមិនច្បាស់លាស់ទៅទៀត បើប្រៀបធៀបទៅនឹងច្បាប់ប្រឆាំងការរម្លូតកូនដ៏ទូលំទូលាយក្នុងទសវត្សឆ្នាំ ១៩៧០ និង បើបៀបធៀប ក្នុងបរិបទនៃកាលៈទេសៈ ដែលប្រជាជនខ្មែរប្រឈមក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ការភ្ជាប់ការប្រព្រឹត្តិនៃការបង្កឲ្យមានផ្ទៃពោះដោយបង្ខំ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទៅនឹងសិទ្ធិជាមូលដ្ឋានច្បាស់លាស់ជាច្រើន ដែលការរំលោភសិទ្ធិទាំងនោះនាំឲ្យមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ ដើម្បីក្លាយជា"អំពើអមនុស្សធម៌ផ្សេងទៀត" នឹងជាប់ពាក់ព័ន្ធដល់កម្រិតនៃភាពស្រពិចស្រពិល ដែលនាំឲ្យរំលោភគោលការណ៍សច្ចភាពនៃច្បាប់។

---

[131] *សូមមើល* សំណើររបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ១២ ដែលបានរៀបរាប់អំពីផលប៉ះពាល់ដែលអាចមើលឃើញលើរាងកាយស្ត្រីពាក់ព័ន្ធនឹងការមានផ្ទៃពោះ ដោយចាត់ទុកការប្រសូត្រ និង មើលថែទាំងកូនដែលមិនចង់បាន, ត្រូវរម្លឹកនឹកឃើញថាកូននោះជាផលនៃការឈ្លានពានលើរូបរាងកាយ ថាជាព្យសនកម្មពីការបង្កឲ្យមានផ្ទៃពោះដោយបង្ខំ។

[132] សំណើររបស់សហព្រះរាជអាជ្ញាអន្តរជាតិ, កថាខណ្ឌ ១០។

[133] *សូមមើល ដូចខាងលើ*, កថាខណ្ឌ ៧១-៧២។

81. ជាទីបញ្ចប់ និយមន័យនៃការបង្កឲ្យមានផ្ទៃពោះរបស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺចង់ឲ្យដាក់ឲ្យក្លាយជាបទល្មើសព្រហ្មទណ្ឌ នូវការប្រព្រឹត្តិដែលមានបទដ្ឋានទាបជាងនេះមួយ (ឧទាហរណ៍ ការបង្ខំឲ្យស្ត្រីណាម្នាក់មានផ្ទៃពោះ) ជាជាងនិយមន័យរបស់លក្ខន្តិកៈទីក្រុងរ៉ូម (ការបង្ខំឲ្យស្ត្រីណាម្នាក់មានផ្ទៃពោះ និង រក្សាឲ្យមានផ្ទៃពោះដោយបង្ខំ)។ ពាក់ព័ន្ធនឹងនីត្យានុកូលភាពនៃនិយមន័យក្នុងលក្ខន្តិកៈទីក្រុងរ៉ូម កាលណាអនុវត្តចំពោះបរិបទនៃប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[134] ផលប៉ះពាល់លើជនត្រូវចោទនឹងមានកម្រិតកាន់តែធ្ងន់ធ្ងរ ប្រសិនបើអនុវត្តតាមរូបមន្តរបស់សហព្រះរាជអាជ្ញាដែលទម្លាក់កម្រិតនៃលក្ខខណ្ឌតម្រូវកាន់តែទាប ក្នុងការដាក់ការប្រព្រឹត្តិឲ្យក្លាយជាបទឧក្រិដ្ឋ។

**ខ) ភាពខ្វះភស្តុតាងដើម្បីគាំទ្រការចោទប្រកាន់**

82. ទោះបីជាការមានផ្ទៃពោះដោយបង្ខំ ឬ ការបង្កឲ្យមានផ្ទៃពោះដោយបង្ខំ ចូលជាធរមានថាជាឧក្រិដ្ឋប្រឆាំងមនុស្សជាតិពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ក៏ដោយ ភស្តុតាងដែលការិយាល័យសហចៅក្រមស៊ើបអង្កេតទទួលបានមករហូតដល់ពេលនេះ មិនគាំទ្រដល់អាត្ថិភាពនៃការអនុវត្តបែបនេះទោះក្នុងកម្រិតដែលអាចវាស់វែងមួយបាន កុំថាឡើយដល់កម្រិតដែលមានលក្ខណៈទូទៅ ឬ ជាប្រព័ន្ធ។ ចំណុចនេះរឹតតែពិតទៅទៀត ចំពោះករណីនៃការមានផ្ទៃពោះដោយបង្ខំ កាលណាអនុវត្តនិយមន័យរបស់លក្ខន្តិកៈទីក្រុងរ៉ូមនៃបទឧក្រិដ្ឋនេះ។

83. សាក្សីនៅក្នុងសំណុំរឿង ០០៤ បញ្ជាក់ថា ពួកគាត់បានសង្កេតឃើញ ឬ បានឮថាមានកងឈ្លបលួចស្តាប់អ្នកដែលទើបរៀបការថ្មីថ្មោង ដើម្បីឲ្យដឹងថាពួកគាត់“*ត្រូវគ្នា*” ជាពាក្យអ្នកស្រុកប្រើសំដៅលើការរួមដំណេករវាងប្តីនិងប្រពន្ធ[135]។ សាក្សីពីររូប ដែលបានចូលរួមក្នុងពិធីរៀបការ បានឮអ្នករៀបការត្រូវ

---

[134] *សូមមើល ដូចខាងលើ*, កថាខណ្ឌ ៦៧-៦៩។

[135] សំណុំរឿងលេខ 004-D219/125, *កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ស្រី សឿម*, ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤, A88។ *សូមមើលផងដែរ* សំណុំរឿងលេខ 004-D219/261, *កំណត់ហេតុស្តាប់ចម្លើយសាក្សី យឿន ស៊ឿន*, ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៥, A59។ សំណុំរឿងលេខ 004-D219/300, *កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ឹម ប៊ុនឈឿន*, ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៥, A10, A18-19។ សំណុំរឿងលេខ 004-D219/42, *កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចិច សុផា*, ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤, A119។ សំណុំរឿងលេខ 004-D219/46, *កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សោម វណ្ណា*, ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤, A93។ សំណុំរឿងលេខ 004-D117/68, *កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី វ៉ា លឹមហ៊ុន*, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤, A34។ សំណុំរឿងលេខ 004-D219/47, *កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ខូវ ណោត*, ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤, A28-31។ សំណុំរឿងលេខ 004-D219/687, *កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ៅ សារឿន*, ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៦, A82។ សំណុំរឿងលេខ 004-D219/171, *កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ញឹម ខុល*, ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥, A44។

បង្គាប់ឲ្យឡើងប្ដេជ្ញាឲ្យបង្កាត់ពូជ ឬ “*បង្កើតកូនដើម្បីកសាងប្រទេស*”[136]។ សាក្សីដទៃទៀត លើកឡើងថា ពួកគាត់មិនបានដឹងថាហេតុអ្វីបានជាគេបង្ខំឲ្យមនុស្សរៀបការ ឬ មិនដឹងថាតើការតាមឈ្លបមើលអ្នករៀបការថ្មីថ្មោង គឺជាការអនុវត្តដើម្បីឲ្យដឹងប្រាកដថាស្ត្រីទាំងនោះនឹងមានផ្ទៃពោះឬយ៉ាងណានោះទេ[137]។ សាក្សីមួយរូប ដែលបានបញ្ជាក់អំពីការឈ្លបមើលអ្នករៀបការថ្មោងថ្មី លើកឡើងថា “*អង្គការមិនចាប់អារម្មណ៍ខ្លាំងលើការមានកូនទេ។ ពួកគេអនុញ្ញាតឲ្យយើងមានកូនតាមធម្មជាតិ*”[138]។

84. សាក្សីត្រូវបានគេនាំឲ្យជឿថា ការដែលមិន“*ត្រូវគ្នា*” គឺនឹងនាំឲ្យអ្នករៀបការនោះ“*រងការស្ដីបន្ទោស*”[139] បញ្ជូនទៅអប់រំ[140] រាយការណ៍ទៅថ្នាក់លើរបស់របបនោះ[141] ឬ រងទារុណ្ណកម្ម[142]។ សាក្សីជាក់លាក់

---

[136] សំណុំរឿងលេខ 004-D219/125, *កំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ស្រី សឿម*, ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤, A97។ សំណុំរឿងលេខ 004-D219/502, *កំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី មួក សេងលី*, ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥, A34-35, A37។

[137] សំណុំរឿងលេខ 004-D219/261, *កំណត់ហេតុស្ដាប់ចម្លើយសាក្សី ឃឿន ស្មឿន*, ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៥, A59-61។ សំណុំរឿងលេខ 004-D219/356, *កំណត់ហេតុស្ដាប់ចម្លើយសាក្សី វ៉ាន់ ណាក់*, ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥, A73 ។ សំណុំរឿងលេខ 004-D219/314, *កំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ចិច សុផា*, ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៥, A21។ សំណុំរឿងលេខ 004-D117/60, *កំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី សុំ ប៉េត*, ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៤, A40។ សំណុំរឿងលេខ 004-D219/442, *កំណត់ហេតុស្ដាប់ចម្លើយសាក្សី ជុំ វង់ ហៅ យក់ ញ៉ូវ ឬ ង៉ូវ*, ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៥, A230។

[138] សំណុំរឿងលេខ 004-D219/113, *កំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី កែវ ធារី*, ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៤, A77។

[139] សំណុំរឿងលេខ 004-D219/123, *កំណត់ហេតុស្ដាប់ចម្លើយសាក្សី ស ឃីម*, ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤, A23។

[140] សំណុំរឿងលេខ 004-D117/68, *កំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី វ៉ា លីមហ៊ុន*, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤, A36-37។ សំណុំរឿងលេខ 004-D117/60, *កំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី សុំ ប៉េត*, ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៤, A31។ សំណុំរឿងលេខ 004-D219/136, *កំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ថន យ៉ង់*, ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៤, A40-42។

[141] សំណុំរឿងលេខ 004-D219/159, *កំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី នី ហួន*, ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥, A136។ សំណុំរឿងលេខ 004-D219/47, *កំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ខូវ ណេត*, ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤, A28។

[142] សំណុំរឿងលេខ 004-D219/47, *កំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ខូវ ណេត*, ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤, A32។

មួយចំនួន ត្រូវប្រធានភូមិ ឬ កងឈ្លបប្រាប់ថា ពួកគាត់នឹងត្រូវយកទៅសម្លាប់ ប្រសិនបើពួកគាត់មិនរួមដំណេកជាមួយប្តីឬប្រពន្ធពួកគាត់[143]។

85. សាក្សីជាច្រើនរាយការណ៍ថា ទោះបីជាពួកគាត់ជឿថា មានគេលបស្តាប់អ្នករៀបការថ្មោងថ្មីក៏ដោយ ពួកគាត់មិនរួមដំណេក ហើយមិនទទួលរងទណ្ឌកម្មដោយសារតែមិនបានរួមដំណេកនេះទេ ដោយសារតែពួកគាត់បង្ហាញឲ្យអ្នកដទៃដឹងថា ពួកគាត់"*ត្រូវគ្នា*"[144]។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ដែលបានផ្តល់ភ័ស្តុតាងប្រភេទនេះ បញ្ជាក់ថាគាត់អត់មានកូនជាមួយប្តីគាត់ទេ និង មិនមានការដាក់ទោសទណ្ឌដោយសារបញ្ហានេះ[145]។

86. សាក្សីម្នាក់លើកឡើងថា គាត់និងប្តីគាត់រួមដំណេកនឹងគ្នានៅថ្ងៃទី ១០ ក្រោយរៀបការ ដោយសារប្តីរបស់គាត់ជឿថា ពួកកងឈ្លបលួចស្តាប់ពួកគាត់ និង ថាបើពួកគាត់មិនរួមដំណេក ពួកគាត់នឹងត្រូវគេយកទៅសម្លាប់[146]។ គាត់មានផ្ទៃពោះប្រាំពីរខែក្រោយរៀបការ ប៉ុន្តែមិនបានបង្ហាញភ័ស្តុតាង ថាគាត់រងការបង្ខិតបង្ខំឲ្យរក្សាគភ៌រហូតសម្រាលកូនគាត់នោះឡើយ[147]។ សាក្សីមួយរូបផ្សេងទៀត ដែលជឿថាគាត់នឹងត្រូវគេយកទៅសម្លាប់ប្រសិនបើគាត់មិនរួមដំណេកជាមួយប្តីគាត់ នៅទីបំផុតចាប់ចិត្តស្រលាញ់ប្តីគាត់ និង ចាប់ផ្តើមមានផ្ទៃពោះនៅមិនយូរប៉ុន្មានមុនកងទ័ពវៀតណាមមកដល់នៅក្នុងឆ្នាំ ១៩៧៩ និង នៅពេលនោះគាត់នៅតែចាប់ចិត្តស្រលាញ់ប្តីគាត់[148]។ របាយការណ៍ស្រដៀងគ្នានេះផ្សេង

---

[143] សំណុំរឿងលេខ 004-D117/68, *កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី វ៉ា លឹមហ៊ុន*, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤, A41-42។ សុំណុំរឿងលេខ 004-D219/83, *កំណត់ហេតុស្តាប់ចម្លើយសាក្សី សួន យឹម*, ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤, A19, A21។ សុំណុំរឿងលេខ 004-D219/113, *កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី កែវ ធារី*, ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៤, A30, A40។

[144] សុំណុំរឿងលេខ 004-D219/125, *កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ស្រី សឿម*, ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤, A145។ សុំណុំរឿងលេខ 004-D219/42, *កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចិច សុផា*, ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤, A120។ សុំណុំរឿងលេខ 004-D219/300, *កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ឹម ប៊ុនឈឿន*, ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៥, A17, A19-20។ សុំណុំរឿងលេខ 004-D219/46, *កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សោម វណ្ណា*, ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤, A94-96។

[145] សុំណុំរឿងលេខ 004-D219/125, *កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ស្រី សឿម*, ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤, A145។

[146] សុំណុំរឿងលេខ 004-D219/356, *កំណត់ហេតុស្តាប់ចម្លើយសាក្សី វ៉ាន់ ណាក់*, ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥, A68។

[147] សុំណុំរឿងលេខ 004-D219/356, *កំណត់ហេតុស្តាប់ចម្លើយសាក្សី វ៉ាន់ ណាក់*, ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៥, A74។

[148] Case File No. 004-D117/68, *កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី វ៉ា លឹមហ៊ុន*, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤, A49-50។

ទៀត ឲ្យដឹងថា បន្ទាប់ពីរួមដំណេកដំបូងដោយសារការភ័យខ្លាច ពួកគាត់ចាប់ចិត្តស្រលាញ់គ្នា និង បន្ត រួមដំណេកដោយស្ម័គ្រចិត្ត[149]។

87. សាក្សីមួយរូបដែលបាននិយាយ ថាគាត់ត្រូវបានប្តីរំលោភបន្ទាប់រៀបការរួច បញ្ជាក់ថាពួកកងឈ្លប ឃ្លាំមើលពួកគាត់ បន្ទាប់ពីករណីរំលោភលើកដំបូងនោះកើតឡើង[150]។ សាក្សីរូបនោះរៀបការក្នុង ឆ្នាំ ១៩៧៦ និង ចាប់ផ្តើមមានផ្ទៃពោះលើកដំបូងក្នុងឆ្នាំ ១៩៧៨[151]។

88. ការវិភាគខាងលើ ដែលឆ្លុះបញ្ចាំងទូទៅលើភស្តុតាងដែលទទួលបានរហូតដល់បច្ចុប្បន្នក្នុងសំណុំរឿង ០០៤ បញ្ជាក់ថា នៅពេលដែលមានភស្តុតាងដែលថាអ្នករៀបការត្រូវបានលើកទឹកចិត្ត ឬ បង្ខំឲ្យរួម ដំណេក គ្មានភស្តុតាងអំពីគម្រោងរបស់របបកម្ពុជាប្រជាធិបតេយ្យ ក្នុងការធ្វើយ៉ាងណាឲ្យស្ត្រីមានផ្ទៃ ពោះក្រោយរៀបការនោះទេ។

89. ដើម្បីទាមទារតាមសំណើរបស់ខ្លួន មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង សហព្រះរាជអាជ្ញាអន្តរ ជាតិ នៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតនេះ អាចធ្វើឲ្យមានផលប៉ះពាល់ដែលមិនចាំបាច់ និង អវិជ្ជមានដល់សេចក្តីត្រូវការផ្នែកអង្គហេតុ ដើម្បីរៀបចំធនធានដែលមានកម្រិតរបស់ការិយាល័យ សហចៅក្រមស៊ើបអង្កេត ក្នុងការបញ្ចប់កិច្ចស៊ើបសួរលើផ្នែកដែលស្មុគស្មាញបំផុតនៃសំណុំរឿង ០០៤ ទោះជាការចោទប្រកាន់លើអំពើហិង្សាផ្លូវភេទ និង យេនឌ័រ ត្រូវបានយកចិត្តទុកដាក់ត្រឹមត្រូវនៅ ក្នុងការពិចារណាលើគោលនយោបាយព្រហ្មទណ្ឌអន្តរជាតិនាពេលថ្មីៗនេះយ៉ាងណាក៏ដោយ។

**គ) ភាពមិនត្រូវពេលវេលានៃសំណើ និង ការពន្យាពេលដោយមិនចាំបាច់**

90. ទោះបីវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង អនុញ្ញាតឲ្យដាក់សំណើសុំកិច្ចស៊ើបសួរ ក្នុងអំឡុងពេលនៃការ ស៊ើបអង្កេតយ៉ាងណាក្តី ដើម្បីសម្រេចលើសំណើទាំងនេះ យើងត្រូវពិចារណាលើផលប៉ះពាល់លើសិទ្ធិ ជនត្រូវចោទ ក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីឆាប់រហ័ស ប្រសិនបើមិនការស៊ើបអង្កេតបន្ថែម និង សេចក្តីត្រូវការក្នុងការធានាឲ្យមានដំណើរការស៊ើបអង្កេតប្រកបដោយប្រសិទ្ធផល និង ប្រសិទ្ធិ

---

[149] សំណុំរឿងលេខ 004-D219/47, *កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ខូវ ណេត*, ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៤, A43-44។ សំណុំរឿងលេខ 004-D219/687, *កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ៅ សារឿន*, ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៦, A84។ សំណុំរឿងលេខ 004-D219/113, *កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី កែវ ធារី*, ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១៤, A58-59, A66។

[150] សំណុំរឿងលេខ 004-D219/24, *កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុខឿន*, ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៤, A47។

[151] សំណុំរឿងលេខ 004-D219/24, *កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុខឿន*, ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៤, A49។

ភាព[152]។ យើងក៏ពិចារណាផងដែរ លើប្រការដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង សហព្រះរាជអាជ្ញាអន្តរជាតិមិនបានចាត់ការប្រកបដោយការយកចិត្តទុកដាក់ត្រឹមត្រូវ ក្នុងការដាក់សំណើនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីបែបនេះ[153]។

91. សេចក្តីយោងមុនដំបូងបង្អស់ ចំពោះការស៊ើបអង្កេតនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងសំណុំរឿង ០០៤ ត្រូវបានធ្វើឡើងនៅក្នុងចម្លើយរបស់សាក្សី ដែលការិយាល័យសហព្រះរាជអាជ្ញាទទួលបាន តាំងពីខែ វិច្ឆិកា ឆ្នាំ ២០០៨[154]។ ភាពពាក់ព័ន្ធនឹងបញ្ហានៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង ការប្រព្រឹត្តិដែលមានព្យសនកម្ម ឬ ស្ថានទម្ងន់នេះ គឺខាងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង សហព្រះរាជអាជ្ញាអន្តរជាតិពិតជាបានដឹងច្បាស់គ្រប់គ្រាន់ តាំងពីពេលនោះមកម្ល៉េះ។

92. ដោយសារការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យជំនុំជម្រះលើកទីបី នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានទទួលកំណត់ហេតុស្តាប់ចម្លើយសាក្សីនិង ដើមបណ្តឹងរដ្ឋប្បវេណីប្រហែល ១,៩៥០ កំណត់ហេតុ ក្នុងសំណើរឿង ០០៤។ ដើម្បីជាប្រយោជន៍ក្នុងការបញ្ជាក់ឱ្យច្បាស់ ផែនការបញ្ចប់ អ.វ.ត.ក នៅលើគេហទំព័រ អ.វ.ត.ក បញ្ជាក់ថា ការស៊ើបអង្កេតត្រូវបានព្យាករណ៍ថានឹងបិទបញ្ចប់នៅត្រីមាសទីបួនក្នុងឆ្នាំ ២០១៦ សម្រាប់ អោ អាន ប្រសិនបើសំណុំរឿងរបស់គាត់ត្រូវបំបែក និង បិទបញ្ចប់នៅត្រីមាសទីពីរក្នុងឆ្នាំ ២០១៦ សម្រាប់ជនជាប់ចោទទាំងពីរ ប្រសិនបើគ្មានដីកាបំបែកសំណុំរឿង[155]។ ភាគីទាំងអស់សុទ្ធបានដឹង ថាការស៊ើបអង្កេតកំពុងវិវឌ្ឍយ៉ាងឿនលឿនទៅមុខច្រើនហើយ។

---

[152] *សូមមើលដូចខាងលើ* កថាខណ្ឌ ៣៤-៣៦។

[153] សំណុំរឿងលេខ 002-D365/2/17, *សាលដីកាលើការពិចារណាឡើងវិញអំពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំដាក់ឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង*, ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ ៥៣។

[154] *សូមមើល ឧទាហរណ៍* សំណុំរឿងលេខ 004-D1.3.11.19, *OCP* បទសម្ភាស៍ *កៅ ចេង*, ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៨។

[155] *ផែនការបញ្ចប់*, កំណែលេខ ៨, ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦, កថាខណ្ឌ ៩, អាចរកបាននៅ < http://www.eccc.gov.kh/en/eccc-completion-plan-revision-8>។ យើងសូមបន្ថែមថា ផែនការបញ្ចប់នេះ ជាវិធានសម្រាប់កំណត់ថវិកា និង មិនបានកំណត់ពេលវេលា ដែលតម្រូវឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ឬ ស្ថាប័នតុលាការដទៃទៀតនៅ អ.វ.ត.ក គោរពតាមដាច់ខាតនោះឡើយ។

93. សិទ្ធិរបស់ អោ អាន និង យឹម ទិត្យ ក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីឆាប់រហ័ស ចាប់ផ្តើមមានភាពពាក់ព័ន្ធ គិតចាប់ពីថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ នៅពេលដែលពួកគាត់ទាំងពីរត្រូវបានជូនដំណឹងអំពីសិទ្ធិក្នុងឋានៈជាជនសង្ស័យ ក្នុងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤[156]។ សំណើសុំកិច្ចស៊ើបសួររបស់មេធាវីដំណាងដើមបណ្តឹងរដ្ឋប្បវេណី និង សហព្រះរាជអាជ្ញាអន្តរជាតិ នឹងតម្រូវឱ្យស្តាប់ចម្លើយសាក្សីជាច្រើនឡើងវិញក្នុងសំណុំរឿង ០០៤ និង ត្រូវស្វែងរកសាក្សីបន្ថែម ដែលប្រការនេះនឹងត្រូវប្រើប្រាស់ធនធានយ៉ាងច្រើនសម្រាប់ស៊ើបអង្កេត និង ពន្យារកិច្ចដំណើរការនិតិវិធី ប៉ះពាល់ដល់សិទ្ធិរបស់ អោ អាន និង យឹម ទិត្យ ក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីឆាប់រហ័ស។

94. ជនត្រូវចោទមានសិទ្ធិដឹងអំពីលក្ខណៈ និង មូលហេតុនៃបទចោទប្រឆាំងពួកគាត់ និង សហចៅក្រមស៊ើបអង្កេតមានករណីយកិច្ច ក្នុងចំណោមកិច្ចការផ្សេងទៀត ក្នុងការធានាឱ្យបាននូវព្រំដែននៃការវិវឌ្ឍផ្នែកនីតិវិធីត្រឹមត្រូវតាមច្បាប់មួយ ដើម្បីកុំឱ្យការស៊ើបអង្កេតក្តោបអ្វីផ្សេងច្រើនទៀត ដែលនាំឱ្យប្រាសចាកពីគោលដៅដែលត្រូវទៅ[157]។ អោ អាន និង យឹម ទិត្យ រងការចោទប្រកាន់ពីបទរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ តាំងពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ នៅពេលមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ សំណើដែលមេធាវីតំណាងដើម បណ្តឹងរដ្ឋប្បវេណី និង សហព្រះរាជអាជ្ញាអន្តរជាតិស្នើនោះ គឺសុំពង្រីកវិសាលភាពនៃបទឧក្រិដ្ឋ ស្ទើរតែប្រាំពីរឆ្នាំ នៅបន្ទាប់ពីភ័ស្តុតាងនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានលេចឡើង និងពីរឆ្នាំនៅបន្ទាប់ពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះត្រូវបានចោទប្រកាន់ជាលើកដំបូង។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឬ សហព្រះរាជអាជ្ញាអន្តរជាតិមិនបានបង្ហាញអំពីមូលហេតុសមស្របដែលនាំឱ្យមានការពន្យារពេលនេះ។ ភាពយឺតយ៉ាវនេះគឺមិនអាចទទួលយកបានទេ ដ្បិតកិច្ចដំណើរការនីតិវិធីក្នុងដំណាក់កាលនេះ ជនត្រូវចោទត្រូវអាចប្រឈមបទចោទថ្មីបន្ថែមទៀត។

95. យើងសូមគូសបញ្ជាក់ផងដែរថា សំណើសុំកិច្ចស៊ើបសួរនេះ គឺជាសំណើលើកដំបូង ដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤ បានស្នើសុំ និង ជាបញ្ហាស៊ើបអង្កេតជាក់ស្តែងដ៏កម្រមួយ ដែលលើកឡើងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤។ ដោយ

---

[156] សុំណុំរឿងលេខ 004-D110, *សេចក្តីជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១(១)(ឃ)*, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២១០២។ សុំណុំរឿងលេខ 004-D109, *សេចក្តីជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១(១)(ឃ)*, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២១០២។

[157] មាត្រា ១៣(៣)(ក) នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ, បញ្ចូលទៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ដោយមាត្រា ៣៣*ថ្មី* នៃច្បាប់ អ.វ.ត.ក។

មូលហេតុនៃកង្វះការពន្យល់អំពីការពន្យារពេលក្នុងការដាក់សំណើរបស់ខ្លួននេះ យើងពិចារណាឃើញថា ទាំងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង សហព្រះរាជអាជ្ញាអន្តរជាតិសុទ្ធតែខកខានក្នុងការអនុវត្តការយកចិត្តទុកដាក់ត្រឹមត្រូវ នៅក្នុងការត្រៀមរៀបចំចូលរួមក្នុងការស៊ើបអង្កេត អនុលោមតាមវិធាន ៥៥(១០)។

96. ដោយសារតែផលប៉ះពាល់ដល់សិទ្ធិរបស់ អោ អាន និង យឹម ទិត្យ ក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ ជាពិសេសសិទ្ធិរបស់ពួកគាត់ក្នុងការទទួលបាននីតិវិធីឆាប់រហ័ស និង ដើម្បីដឹងអំពីលក្ខណៈ និង មូលហេតុនៃសំណុំរឿងប្រឆាំងពួកគាត់ ការពន្យារពេលដែលមិនចាំបាច់ដែលនឹងបណ្តាលមកពីការបំពេញកិច្ចស៊ើបសួរ នៅក្នុងដំណាក់កាលនៃនីតិវិធីនេះ គឺជាកត្តាសំខាន់គ្រប់គ្រាន់មួយ ក្នុងការបដិសេធសំណើទាំងពីរនេះ។

97. ដូច្នេះ យើងគប្បីជូនដំណឹងជាផ្លូវការ ជាពិសេសដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង សហព្រះរាជអាជ្ញាអន្តរជាតិ ឲ្យបានជ្រាបក្នុងពេលនេះថា យើងនឹងពិបាកទទួលយកសំណើសុំពង្រីកវិសាលភាពនៃកិច្ចស៊ើបសួរ ដោយបញ្ចូលការចោទប្រកាន់ថ្មីនៃសេណារីយោអង្គហេតុ ដែលកំណត់បទល្មើសថ្មីបន្ថែមទៀតណាស់ លើកលែងតែមានមូលហេតុសមស្របពិសេសណាមួយ ជាមុនសិន។ ក្នុងករណីនេះ គឺមិនមានទេ។

**ឃ) អង្គហេតុដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម**

98. ទោះបីមេធាវីការពារក្តី យឹម ទិត្យ ធ្វើត្រូវក្នុងការលើកឡើងថា ពុំមានសេចក្តីយោងច្បាប់លាស់ទៅនឹងការមានផ្ទៃពោះដោយបង្ខំ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមយ៉ាងណាក្តី[158] ប្រសិនបើយើងបែរជាសន្និដ្ឋានថា កិច្ចស៊ើបសួរបន្ថែមត្រូវតែអនុញ្ញាឲ្យធ្វើ លើភ័ស្តុតាងដែលបានរហូតដល់ពេលបច្ចុប្បន្ន ប៉ុន្តែអង្គហេតុដែលត្រូវបានចោទប្រកាន់នោះស្ថិតក្រៅវង្វង់នៃវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម នោះច្បាស់ជាមានករណីមួយទៀត ដែលត្រូវបញ្ជូនដីកានេះបន្តទៅសហព្រះរាជអាជ្ញាអន្តរជាតិ សុំសេចក្តីបញ្ជាក់លើវិសាលភាពនៃកិច្ចស៊ើបសួរនេះ។ ទោះជាយ៉ាងណាក៏ដោយ ឧបមាថាមានគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យ ក្នុងការបង្កើនចំនួនប្រជាជន តាមរយៈការអនុវត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នោះការមានផ្ទៃពោះដោយបង្ខំ ឬ ការបង្កឲ្យមានផ្ទៃ

[158] សារណាតបរបស់មេធាវីការពារក្តី កថាខណ្ឌ ១៧, ២០។

ពោះដោយបង្កំ អាចត្រូវចាត់ទុកថាជាការអនុវត្តមួយដែលអាចប្រមើលមើលឃើញ ឬ ទំនងជាមានផលវិបាក របស់វា និង ត្រូវតែស្ថិតក្នុងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

99. ដីកាសម្រេចនេះដាក់ជាភាសាអង់គ្លេស ដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

**តាមសម្អាងហេតុខាងលើ យើង៖**

100. **បដិសេធ**សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង សហព្រះរាជអាជ្ញាអន្តរជាតិ។

ភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦

**ចៅក្រម** Michael Bohlander

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

International Co-Investigating Judge

Co-juge d'instruction international